ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់

# ស្តីពី

# ទេសចរណ៍

ព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩

នាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស

# ព្រះរាជក្រម

នស/រកម/០៦០៩/០០៧

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងទេសចរណ៍

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីទេសចរណ៍ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី ២ នីតិកាលទី ៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៩ នាសម័យប្រជុំវិសាមញ្ញ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ:

UME du CAMBODGE *

# ច្បាប់

# ស្ដីពី

# ទេសចរណ៍

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី ១

# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅកំណត់វិធាន និងយន្តការសម្រាប់គ្រប់គ្រងនិងអភិវឌ្ឍវិស័យទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

ច្បាប់នេះមានគោលបំណង ដូចតទៅ :

-គ្រប់គ្រង និងអភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយប្រសិទ្ធភាព គុណភាព និងនិរន្តរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រ

-រួមចំណែកការពារ និងថែរក្សាធនធានធម្មជាតិ វប្បធម៌ និងទំនៀមទម្លាប់ដែលជាមូលដ្ឋានបម្រើឱ្យវិស័យទេសចរណ៍

-ធានា និងលើកកម្ពស់គុណភាពសេវាកម្មទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈការបង្កើតប្រព័ន្ធធានាគុណភាព ដោយផ្តល់សន្តិសុខ សុវត្ថិភាព ផាសុកភាព និងបង្កើនការពេញចិត្តដល់ទេសចរ

-ទាញយកផលប្រយោជន៍ក្នុងវិស័យទេសចរណ៍ឱ្យបានជាអតិបរមា ធានាការបែងចែកប្រកបដោយសមធម៌ និងទប់ស្កាត់ផលប៉ះពាល់អវិជ្ជមាននៃវិស័យទេសចរណ៍

-លើកកម្ពស់កិច្ចសហប្រតិបត្តិការទូលំទូលាយ រកទីផ្សារ និងជំរុញការផ្សព្វផ្សាយទេសចរណ៍កម្ពុជាឱ្យកាន់តែមានប្រសិទ្ធភាព ដោយមានការចូលរួមពីផ្នែកសាធារណៈ និងផ្នែកឯកជន

-អភិវឌ្ឍធនធានមនុស្សក្នុងវិស័យទេសចរណ៍

-រួមចំណែកកសាងមិត្តភាព និងការយោគយល់ជាអន្តរជាតិ តាមរយៈឧស្សាហកម្មទេសចរណ៍ ។

**មាត្រា ៣.-**

ច្បាប់នេះមានវិសាលភាពគ្រប់គ្រងនិងគ្របដណ្តប់លើរាល់សកម្មភាពទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤.-**

វាក្យស័ព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ ត្រូវកំណត់នៅក្នុងឧបសម្ព័ន្ធ ។

## ជំពូកទី ២

## គោលនយោបាយ និងផែនការអភិវឌ្ឍទេសចរណ៍

**មាត្រា ៥.-**

ក្រសួងទេសចរណ៍ ត្រូវរៀបចំគោលនយោបាយ និងផែនការអភិវឌ្ឍទេសចរណ៍សម្រាប់ព្រះរាជាណាចក្រកម្ពុជា ដោយមានការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ សមាគមឧស្សាហកម្មទេសចរណ៍ និង ផ្នែកឯកជនដែលមានការពាក់ព័ន្ធ ។

ផែនការអភិវឌ្ឍទេសចរណ៍ រួមមាន ផែនការអភិវឌ្ឍទេសចរណ៍ថ្នាក់ជាតិ ផែនការអភិវឌ្ឍទេសចរណ៍ថ្នាក់តំបន់ និងផែនការអភិវឌ្ឍទេសចរណ៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។ រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំផែនការអភិវឌ្ឍទេសចរណ៍ សម្រាប់មូលដ្ឋានរបស់ខ្លួន ។

**មាត្រា ៦.-**

ផែនការអភិវឌ្ឍទេសចរណ៍ថ្នាក់ជាតិ ត្រូវ ៖

ក-កំណត់គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការជាតិសម្រាប់ការអភិវឌ្ឍ និងផ្សព្វផ្សាយអំពីវិស័យទេសចរណ៍កម្ពុជា ។

ខ-លើកឡើងរាល់វិធានការ ដើម្បីកាត់បន្ថយភាពក្រីក្រ និងធានាឱ្យបាននូវនិរន្តរភាពនៃការអភិវឌ្ឍវិស័យទេសចរណ៍ថ្នាក់ជាតិ ។

គ-ធ្វើសមាហរណកម្មជាមួយផែនការទេសចរណ៍អាស៊ាននិងផែនការទេសចរណ៍អន្តរជាតិនានា ។

**មាត្រា ៧.-**

ផែនការអភិវឌ្ឍទេសចរណ៍ថ្នាក់តំបន់ និងផែនការអភិវឌ្ឍទេសចរណ៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវ ៖

ក-កំណត់យុទ្ធសាស្ត្រអភិវឌ្ឍវិស័យទេសចរណ៍តាមតំបន់ និងនៅថ្នាក់រដ្ឋបាលខ្លួន ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

Ksl

ខ-លើកឡើងនូវវិធានការនានាដើម្បីកាត់បន្ថយភាពក្រីក្រ និងដើម្បីធានាឱ្យបាននូវនិរន្តរភាពនៃការអភិវឌ្ឍ និងការគ្រប់គ្រងវិស័យទេសចរណ៍ នៅតាមតំបន់ និងនៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិ ។

ផែនការអភិវឌ្ឍទេសចរណ៍ថ្នាក់តំបន់ ត្រូវរៀបចំឡើងឱ្យស្របទៅតាមផែនការអភិវឌ្ឍទេសចរណ៍ថ្នាក់ជាតិ ។ ផែនការអភិវឌ្ឍទេសចរណ៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំឡើងឱ្យស្របទៅតាមផែនការអភិវឌ្ឍទេសចរណ៍ថ្នាក់តំបន់ ។

**មាត្រា ៨.-**

ផែនការអភិវឌ្ឍទេសចរណ៍ថ្នាក់ជាតិ និងថ្នាក់តំបន់ ត្រូវដាក់ជូនរាជរដ្ឋាភិបាល ដើម្បីអនុម័ត និងបញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ដើម្បីឱ្យក្លាយទៅជាគោលនយោបាយ និងយុទ្ធសាស្ត្រទូទៅរបស់រាជរដ្ឋាភិបាលសម្រាប់វិស័យទេសចរណ៍នៅព្រះរាជាណាចក្រកម្ពុជា ។

ផែនការអភិវឌ្ឍទេសចរណ៍ត្រូវពិនិត្យ និងកែប្រែឡើងវិញតាមភាពចាំបាច់ យ៉ាងហោចណាស់មួយដងរៀងរាល់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ។

## ជំពូកទី ៣
## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា ៩.-**

ក្រសួងទេសចរណ៍មានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងការងារវិស័យទេសចរណ៍និងបំពេញភារកិច្ចផ្សេងៗទៀតឱ្យមានប្រសិទ្ធភាពស្របទៅតាមការអនុវត្តជាលក្ខណៈជាតិ និងអន្តរជាតិ ។

ក្រសួងទេសចរណ៍ត្រូវដឹកនាំ និងត្រួតពិនិត្យការអនុវត្តផែនការអភិវឌ្ឍទេសចរណ៍ ។ ដោយវិស័យទេសចរណ៍ប៉ះពាល់ទៅលើ និងទទួលរងការប៉ះពាល់ពីការងារ និងសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន និងអាជ្ញាធរជាច្រើនទៀត ការបែងចែកតួនាទីរបស់ក្រសួងទេសចរណ៍ជាទូទៅ ត្រូវធ្វើឡើងស្របទៅតាមគោលការណ៍ដែលបានគូសបញ្ជាក់នៅក្នុងមាត្រានានាផ្សេងៗនៃច្បាប់នេះ ។

**មាត្រា ១០.-**

ក្រសួងទេសចរណ៍ ត្រូវទទួលខុសត្រូវជាចម្បងក្នុងការចេញបទប្បញ្ញត្តិសំខាន់ៗផ្នែកឧស្សាហកម្មទេសចរណ៍ ដើម្បីជំរុញការអនុវត្តផែនការអភិវឌ្ឍទេសចរណ៍ឱ្យមានប្រសិទ្ធភាព ផ្នែកសំខាន់ៗទាំងនោះ រួមមាន :

-ការផ្សព្វផ្សាយវិស័យទេសចរណ៍ក្នុង និងក្រៅព្រះរាជាណាចក្រកម្ពុជា

-ការធានាគុណភាពនៅក្នុងវិស័យទេសចរណ៍

-ស្តង់ដារនានានៃវិស័យទេសចរណ៍

-អាជ្ញាបណ្ណទេសចរណ៍

-សកម្មភាពអាជីវកម្មទេសចរណ៍

-ការណែនាំភាគីពាក់ព័ន្ធក្នុងវិស័យទេសចរណ៍

-ការគ្រប់គ្រង និងការត្រួតពិនិត្យព័ត៌មានទេសចរណ៍

-សហប្រតិបត្តិការអន្តរជាតិក្នុងវិស័យទេសចរណ៍ ជាមួយប្រទេសជិតខាង និងពិភពលោក ។

ក្រសួងទេសចរណ៍ត្រូវពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន និង អាជ្ញាធរពាក់ព័ន្ធក្នុងករណីដែលក្រសួង ស្ថាប័ន ឬ អាជ្ញាធរណាមួយនោះ មានចំណាប់អារម្មណ៍ប្រឹក្សាយោបល់លើផ្នែកណាមួយនៃឧស្សាហកម្មទេសចរណ៍ ។

**មាត្រា ១១.-**

ក្រសួងទេសចរណ៍ត្រូវមានការទទួលខុសត្រូវរួមគ្នាជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធដទៃទៀត ក្នុងការចេញបទប្បញ្ញត្តិសំខាន់ៗដែលប៉ះពាល់ទៅលើ ឬ ទទួលរងការប៉ះពាល់ដោយឧស្សាហកម្មទេសចរណ៍ ។ ផ្នែកសំខាន់ៗទាំងនោះ រួមមាន :

-សមាគមឧស្សាហកម្មទេសចរណ៍

-ការការពារបរិស្ថាន

-ការការពារ និងការបង្ហាញពីមរតកធម្មជាតិ

-ការការពារ និងការបង្ហាញពីមរតកវប្បធម៌

-ការវិនិយោគវិស័យទេសចរណ៍ និងការលើកទឹកចិត្ត

-ការគ្រប់គ្រង និងឯកជនភាវូបនីយកម្មនៃសហគ្រាសទេសចរណ៍របស់រដ្ឋ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

Ksl

-ការគ្រប់គ្រងដីធ្លីរបស់រដ្ឋដែលបានផ្តល់សម្រាប់គោលបំណងទេសចរណ៍

-ការទប់ស្កាត់ការធ្វើអាជីវកម្មផ្លូវភេទ

-ការអភិវឌ្ឍផលិតផលទេសចរណ៍

-អេកូទេសចរណ៍

-សហគមន៍ទេសចរណ៍មូលដ្ឋាន

-ការកាត់បន្ថយភាពក្រីក្រ

-អនាម័យ និងសុវត្ថិភាពចំណីអាហារ

-សន្តិសុខ និងសុវត្ថិភាពទេសចរ

-នគរបាលទេសចរណ៍ ។

ក្រសួងទេសចរណ៍ ក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធ ត្រូវសហការគ្នា ដើម្បីធានាថាផ្នែកនានានៅក្នុងឧស្សាហកម្មទេសចរណ៍ត្រូវបានចាត់ចែង និងគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងឆ្លើយតបទៅតាមផែនការអភិវឌ្ឍទេសចរណ៍ ។

**មាត្រា ១២.-**

ក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធដែលការងាររបស់ខ្លួនប៉ះពាល់ទៅដល់ឧស្សាហកម្មទេសចរណ៍ និងផែនការអភិវឌ្ឍទេសចរណ៍ ត្រូវពិគ្រោះយោបល់ផ្នែកជំនាញទេសចរណ៍ពីក្រសួងទេសចរណ៍ ។ ផ្នែកដែលប៉ះពាល់ទៅលើ ឬ ទទួលរងការប៉ះពាល់ដោយឧស្សាហកម្មទេសចរណ៍ អាចរួមមាន :

-ផែនការប្រើប្រាស់ដីធ្លី

-ផែនការរូបវន្ត និងផែនការអភិវឌ្ឍ

-ហេដ្ឋារចនាសម្ព័ន្ធ និងសេវាសាធារណៈ

-ការផ្តល់ឱ្យភាពជាម្ចាស់កម្មសិទ្ធិ ភតិសន្យា ឬ សម្បទានសម្រាប់គោលបំណងទេសចរណ៍

-ការកសាងគោលនយោបាយពន្ធដារលើអាជីវកម្មទេសចរណ៍

-ទិដ្ឋាការ

-គោលនយោបាយអាកាសចរណ៍ ។

ROYAUME DU CAMBODGE * ... ROYAL

ដើម្បីធានាការអនុវត្តឱ្យមានប្រសិទ្ធភាព រាល់គម្រោងសាងសង់សំណង់បម្រើឱ្យសកម្មភាពទេសចរណ៍ ត្រូវធ្វើឡើងឱ្យស្របតាមផែនការអភិវឌ្ឍទេសចរណ៍ និង ត្រូវមានការជួយយោបល់ផ្នែកជំនាញទេសចរណ៍ពីក្រសួងទេសចរណ៍ ។

ក្រសួងទេសចរណ៍ ជួយផ្តល់ដំបូន្មានបច្ចេកទេស ទៅដល់គណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍទេសចរណ៍រាជធានី ខេត្ត និងថ្នាក់មូលដ្ឋាន ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារនិងផ្សព្វផ្សាយទេសចរណ៍កម្ពុជា សមាគមឧស្សាហកម្មទេសចរណ៍ និងប្រតិបត្តិករទេសចរណ៍ ។

**មាត្រា ១៣.-**

ក្នុងករណីចាំបាច់ ក្រសួងទេសចរណ៍ព្រមទាំងក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធ អាចចេញបទប្បញ្ញត្តិផ្សេងៗរួមគ្នា ដើម្បីចាត់ចែង និងគ្រប់គ្រងការងារដូចមានចែងក្នុងមាត្រា ១១ និងមាត្រា ១២ នៃច្បាប់នេះឱ្យមានប្រសិទ្ធភាព ។

## ជំពូកទី ៤
## ស្ថាប័ន និងហិរញ្ញប្បទាន

**មាត្រា ១៤.-**

ក្រសួងទេសចរណ៍ត្រូវពង្រឹង និងពង្រីករចនាសម្ព័ន្ធចាត់តាំងរបស់ខ្លួនឱ្យឆ្លើយតបតាមផែនការអភិវឌ្ឍទេសចរណ៍ ។

**មាត្រា ១៥.-**

ក្រសួងទេសចរណ៍ត្រូវរៀបចំបង្កើតវិទ្យាស្ថានជាតិទេសចរណ៍ ។ វិទ្យាស្ថានជាតិទេស-ចរណ៍ជាមណ្ឌលសិក្សា និងស្រាវជ្រាវអំពីវិស័យទេសចរណ៍ក្នុងគោលបំណងបង្កើតគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍទេសចរណ៍ប្រកបដោយប្រសិទ្ធភាព គុណភាព និងនិរន្តរភាព ។ ការរៀបចំ និងការប្រព្រឹត្តទៅនៃវិទ្យាស្ថានជាតិទេសចរណ៍នេះត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១៦.-**

ក្រសួងទេសចរណ៍ត្រូវរៀបចំបង្កើតសាលាវិជ្ជាជីវៈទេសចរណ៍ ។ សាលាវិជ្ជាជីវៈទេសចរណ៍នេះមានបេសកកម្មអប់រំបណ្ដុះបណ្ដាល អ្នកឯកទេសវិជ្ជាជីវៈផ្នែកទេសចរណ៍

សណ្ឋាគារ និងបដិសណ្ឋារកិច្ចសំដៅបម្រើឱ្យឧស្សាហកម្មទេសចរណ៍ ។ ការរៀបចំ និងការប្រព្រឹត្តទៅនៃសាលាវិជ្ជាជីវៈទេសចរណ៍នេះត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១៧.-**

ក្រសួងទេសចរណ៍ត្រូវរៀបចំបង្កើតសកលវិទ្យាល័យទេសចរណ៍ និងបដិសណ្ឋារកិច្ច ។ សកលវិទ្យាល័យទេសចរណ៍ និងបដិសណ្ឋារកិច្ចជាគ្រឹះស្ថានឧត្តមសិក្សាដែលមានការអប់រំ និងបណ្តុះបណ្តាលធនធានមនុស្សលើគ្រប់ជំនាញនៃវិស័យទេសចរណ៍ និងបដិសណ្ឋារកិច្ច ។ ការរៀបចំ និងការប្រព្រឹត្តទៅនៃសកលវិទ្យាល័យទេសចរណ៍ និងបដិសណ្ឋារកិច្ចត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១៨.-**

ក្រសួងទេសចរណ៍សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធត្រូវទទួលស្គាល់តួនាទីដ៏មានតម្លៃរបស់ផ្នែកឯកជនក្នុងការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជំនាញទេសចរណ៍ សណ្ឋាគារ និងបដិសណ្ឋារកិច្ច ដូចបានកំណត់ក្នុងបទប្បញ្ញត្តិនានាដែលមានចែងក្នុងជំពូកទី ៥ នៃច្បាប់នេះ ។

**មាត្រា ១៩.-**

ក្រសួងទេសចរណ៍ជួយសម្រួលការងារទាំងឡាយក្នុងការបង្កើតធម្មនុញ្ញ និង/ឬ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងត្រួតពិនិត្យសកម្មភាពរបស់សមាគមឧស្សាហកម្មទេសចរណ៍ ។

សមាគមឧស្សាហកម្មទេសចរណ៍ត្រូវមានធម្មនុញ្ញ និង/ឬ លក្ខន្តិកៈ ឬ បទបញ្ជាផ្ទៃក្នុងឱ្យស្របទៅតាមច្បាប់ និងបទប្បញ្ញត្តិផ្សេងៗជាធរមាន ។

**មាត្រា ២០.-**

ក្រសួងទេសចរណ៍ត្រូវរៀបចំបង្កើតក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និង ផ្សព្វផ្សាយទេសចរណ៍កម្ពុជាមានអក្សរកាត់ថា "ក.ផ.ផ." ក្នុងលក្ខណៈជាដៃគូជាមួយផ្នែកឯកជននិងផ្នែកសាធារណៈ ។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជាត្រូវកំណត់ដោយអនុក្រឹត្យ ។

ROYAUME DU CAMBODGE
ទីស្តីការគណៈរដ្ឋមន្ត្រី
MINISTRE DU PALAIS ROYAL

**មាត្រា ២១.-**

ហិរញ្ញប្បទានទ្រទ្រង់ការអភិវឌ្ឍ និងគ្រប់គ្រងវិស័យទេសចរណ៍បានមកពី :

-ថវិកាជាតិប្រចាំឆ្នាំរបស់ក្រសួងទេសចរណ៍

-ហិរញ្ញប្បទានសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍនានា

-ការបរិច្ចាគរបស់សប្បុរសជន អតិថិជន និងសមាគមឧស្សាហកម្មទេសចរណ៍

-ការបរិច្ចាគរបស់ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា

-ការបរិច្ចាគរបស់ប្រតិបត្តិករទេសចរណ៍

-ប្រភពហិរញ្ញប្បទាន ឬ ចំណូលស្របច្បាប់ផ្សេងៗទៀត ។

ការគ្រប់គ្រង និងការប្រើប្រាស់ថវិកាសម្រាប់អភិវឌ្ឍវិស័យទេសចរណ៍ ត្រូវកំណត់ដោយប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ៥

## គុណភាព ស្តង់ដារ និងអាជ្ញាបណ្ណទេសចរណ៍

**មាត្រា ២២.-**

ក្រសួងទេសចរណ៍ត្រូវត្រួតពិនិត្យលើការចាត់ចែងរាល់អាជីវកម្ម និងសកម្មភាពទេសចរណ៍តាមរយៈការផ្តល់អាជ្ញាបណ្ណ ការបង្កើតប្រព័ន្ធចំណាត់ថ្នាក់ កំណត់ស្តង់ដារ អប្បបរមា និងប្រព័ន្ធអនុវត្តទានានាដើម្បីបង្កើត កែលំអ និងរក្សាគុណភាពសេវាកម្មទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២៣.-**

ក្រសួងទេសចរណ៍ត្រូវកំណត់ស្តង់ដារ និងការតម្រូវលើបញ្ហាបច្ចេកទេសសេវាកម្មទេសចរណ៍ឱ្យស្របទៅនឹងលក្ខខណ្ឌអនុវត្តដ៏ប្រសើរបំផុត នៅក្នុងព្រះរាជាណាចក្រកម្ពុជា អាជីវកម្មទេសចរណ៍ទាំងអស់ត្រូវអនុវត្តទៅតាមស្តង់ដារ និងការតម្រូវ ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ។

ROYAUME DU CAMBODGE

**មាត្រា ២៤.-**

ក្រសួងទេសចរណ៍ត្រូវរៀបចំបង្កើតប្រព័ន្ធចំណាត់ថ្នាក់សណ្ឋាគារនិង សេវាកម្មស្នាក់នៅទេសចរណ៍ និងសេវាកម្មទេសចរណ៍ផ្សេងៗទៀតស្របទៅតាមស្តង់ដារអន្តរជាតិ និងលក្ខខណ្ឌអនុវត្តដ៏ប្រសើរបំផុតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ប្រព័ន្ធចំណាត់ថ្នាក់សណ្ឋា-គារនិងសេវាកម្មស្នាក់នៅទេសចរណ៍ត្រូវកំណត់ដោយអនុក្រឹត្យ ។ ប្រព័ន្ធចំណាត់ថ្នាក់សម្រាប់សេវាកម្មទេសចរណ៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ។

**មាត្រា ២៥.-**

ក្រោយពេលប្រព័ន្ធចំណាត់ថ្នាក់ត្រូវបង្កើតឡើងសម្រាប់សកម្មភាពអាជីវកម្មទេស-ចរណ៍ណាមួយនោះ អាជ្ញាបណ្ណទេសចរណ៍ដែលចេញក្រោមច្បាប់នេះ ត្រូវបញ្ជាក់ពីកម្រិតថ្នាក់របស់អាជីវកម្មនោះ ។

**មាត្រា ២៦.-**

ក្រសួងទេសចរណ៍ត្រូវណែនាំវិធានការ សម្រាប់បង្កើនការធានាគុណភាពសេវាកម្មទេសចរណ៍ផ្សេងទៀត ដូចជាស្លាកសញ្ញាពិសេស ស្លាកសញ្ញាបញ្ជាក់គុណភាព ការទទួលស្គាល់គុណភាព រង្វាន់ និងការលើកទឹកចិត្ត ។

ក្រសួងទេសចរណ៍ ត្រូវពិគ្រោះយោបល់ជាមួយឧស្សាហកម្មទេសចរណ៍ និងក្រុមអ្នកពាក់ព័ន្ធផ្សេងៗ ក្នុងការរៀបចំគំនូសប្លង់ ការអភិវឌ្ឍ និងការអនុវត្តវិធានការទាំងនោះ ។

លក្ខណៈពិសេសនៃស្លាកសញ្ញាពិសេស ស្លាកសញ្ញាបញ្ជាក់គុណភាព ការទទួលស្គាល់គុណភាព រង្វាន់ និងការលើកទឹកចិត្តត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ។

**មាត្រា ២៧.-**

ដើម្បីលើកទឹកចិត្តចំពោះការធានាគុណភាពផលិតផល និងសេវាកម្មក្នុងឧស្សាហកម្មទេសចរណ៍ ក្រសួងទេសចរណ៍ត្រូវបង្កើតស្លាកសញ្ញាបរិស្ថានពិសេស មួយហៅថា "**អេកូឡាប៊ិល**" ទុកជូនជារង្វាន់លើកទឹកចិត្តដល់ប្រតិបត្តិករទេសចរណ៍ណាដែលបានអនុវត្តត្រឹមត្រូវតាមស្តង់ដារបរិស្ថានរបស់ក្រសួងបរិស្ថាន ។ មានតែប្រតិបត្តិករទេសចរណ៍ ដែលជាអ្នក

ROYAUME DU CAMBODGE • PALAIS ROYAL

បានទទួលរង្វាន់សញ្ញាបរិស្ថានពិសេសទេ ទើបអាចប្រើប្រាស់ស្លាកនេះ សម្រាប់បិទនៅលើផលិតផល និងសេវាកម្មបម្រើឱ្យសាធារណជន និងអតិថិជនរបស់គេបាន ។

**មាត្រា ២៨.-**

ប្រតិបត្តិករទេសចរណ៍ដែលជាម្ចាស់ស្លាកសញ្ញាបរិស្ថានពិសេស ដែលផ្តល់ដោយក្រសួងទេសចរណ៍ អាចទទួលបានអត្ថប្រយោជន៍ និងការលើកទឹកចិត្តជាអាទិភាពពីរាជរដ្ឋាភិបាលមុនប្រតិបត្តិករទេសចរណ៍ដទៃទៀត ។ ក្នុងចំណោមអត្ថប្រយោជន៍ និងការលើកទឹកចិត្តទាំងនោះមាន :

-សិទ្ធិក្នុងការធ្វើអាជីវកម្មក្នុងតំបន់ពិសេសមួយចំនួន
-ការកាត់បន្ថយថ្លៃចេញអាជ្ញាបណ្ណទេសចរណ៍
-ការផ្សព្វផ្សាយនៅក្នុងប្រព័ន្ធគេហទំព័រអ្នកទទួលរង្វាន់ពិសេស
-ការផ្សព្វផ្សាយនៅក្នុងសៀវភៅអ្នកទទួលរង្វាន់ពិសេស
-ការទទួលអាទិភាពនៅក្នុងយុទ្ធនាការផ្សព្វផ្សាយ ។

**មាត្រា ២៩.-**

ប្រតិបត្តិករទេសចរណ៍ដែលផ្តល់សេវាកម្មល្អ អាចទទួលរង្វាន់ពិសេសពីក្រសួងទេសចរណ៍ ឬ រាជរដ្ឋាភិបាល ឬ ពីព្រះមហាក្សត្រ ។ នីតិវិធី និងលក្ខណវិនិច្ឆ័យលម្អិតសម្រាប់រង្វាន់ពិសេសនេះត្រូវកំណត់ដោយអនុក្រឹត្យ ។

មានតែប្រតិបត្តិករទេសចរណ៍ដែលបានទទួលនូវរង្វាន់ពិសេសនេះទេ ទើបអាចប្រើប្រាស់រង្វាន់ពិសេសនេះបាន នៅក្នុងការទាក់ទងជាមួយសាធារណជន និង អតិថិជនរបស់គេ ។

**មាត្រា ៣០.-**

សកម្មភាពអាជីវកម្មទេសចរណ៍ ដូចចែងក្នុងជំពូកទី ៣ នៃច្បាប់នេះ ត្រូវបានចាត់ទៅតាមប្រភេទ និងការទទួលខុសត្រូវរបស់ក្រសួងទេសចរណ៍ ដូចតទៅ :

**ក- សកម្មភាពអាជីវកម្មទេសចរណ៍នៅក្នុងផ្នែកដែលមានការទទួលខុសត្រូវជាទម្ងន់** ដូចមានចែងក្នុងមាត្រា ១០ នៃច្បាប់នេះ មានជាអាទិ៍ដូចតទៅ :

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

Ksl

-មគ្គុទ្ទេសក៍ទេសចរណ៍

-ការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍

-ព័ត៌មាន និងការផ្សព្វផ្សាយទេសចរណ៍

-សេវាកម្មស្នាក់នៅទេសចរណ៍

-រមណីយដ្ឋានទេសចរណ៍

-គោលដៅទាក់ទាញទេសចរណ៍

-សេវាកម្មដឹកជញ្ជូនទេសចរណ៍

-អាហារដ្ឋាន និងភោជនីយដ្ឋានទេសចរណ៍

-សាលាវិជ្ជាជីវៈទេសចរណ៍

-មណ្ឌលកម្សាន្តទេសចរណ៍

-មណ្ឌលកម្សាន្តទេសចរណ៍សម្រាប់មនុស្សពេញវ័យ

-សកម្មភាពកីឡាទេសចរណ៍

-ព្រឹត្តការណ៍ និងពិព័រណ៍ទេសចរណ៍ ។

**ខ- សកម្មភាពអាជីវកម្មទេសចរណ៍នៅក្នុងផ្នែកដែលមានការទទួលខុសត្រូវរួមគ្នា** ដូចមានចែងក្នុងមាត្រា ១១ នៃច្បាប់នេះ មានជាអាទិ៍ដូចតទៅ :

-អាហារដ្ឋាន និងភោជនីយដ្ឋានទទួលបម្រើភ្ញៀវក្នុងស្រុក

-សេវាកម្មដឹកជញ្ជូនអ្នកធ្វើដំណើរក្នុងស្រុក

-តំបន់ការពារធម្មជាតិ

-តំបន់សត្វស្លាបទន្លេមេគង្គ

-សកម្មភាពអេកូទេសចរណ៍

-សកម្មភាពសហគមន៍ទេសចរណ៍មូលដ្ឋាន

-សេវាកម្មលក់ដូរវត្ថុអនុស្សាវរីយ៍

-គ្រឹះស្ថានសិក្សាទេសចរណ៍ សណ្ឋាគារ និងបដិសណ្ឋារកិច្ច ។

**គ- សកម្មភាពអាជីវកម្មទេសចរណ៍នៅក្នុងផ្នែកដែលមានការទទួលខុសត្រូវដោយ** [illegible] ដូចមានចែងក្នុងមាត្រា ១២ នៃច្បាប់នេះ មានជាអាទិ៍ ដូចតទៅ :

-ការដឹកជញ្ជូនអ្នកធ្វើដំណើរតាមផ្លូវអាកាស

-ទីតាំងបេតិកភណ្ឌវប្បធម៌របស់ជាតិ

-ទីតាំងបេតិកភណ្ឌធម្មជាតិរបស់ជាតិ

-សេវាកម្មរៀបចំសន្និសីទ ពិព័រណ៍ ព្រឹត្តិការណ៍ និងបុណ្យជាតិ អន្តរជាតិ ។

ក្រសួងទេសចរណ៍អាចធ្វើការកែសម្រួលប្រភេទនៃសកម្មភាពអាជីវកម្មទេសចរណ៍ និងការទទួលខុសត្រូវរបស់ខ្លួនបានស្របតាមការចាំបាច់ ឬ ការតម្រូវដែលមានកំណត់នៅក្នុងផែនការអភិវឌ្ឍទេសចរណ៍ ។

**មាត្រា ៣១.-**

ដើម្បីអនុវត្តឱ្យស្របតាមមាត្រា ១០ នៃជំពូកទី ៣ និងបទប្បញ្ញត្តិដែលមានចែងក្នុងជំពូកទី ៥ នៃច្បាប់នេះ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ត្រូវចេញប្រកាស ដើម្បីគ្រប់គ្រងការផ្តល់អាជ្ញាបណ្ណលើសកម្មភាពអាជីវកម្មទេសចរណ៍ តាមផ្នែកដែលក្រសួងទេសចរណ៍ទទួលខុសត្រូវជាចម្បង ។

ក្រសួងទេសចរណ៍ព្រមទាំងក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធ ត្រូវសហការចេញប្រកាសរួម ដើម្បីគ្រប់គ្រងផ្នែកដែលមានការទទួលខុសត្រូវរួមឱ្យស្របតាមមាត្រា ១១ នៃជំពូកទី ៣ និងបទប្បញ្ញត្តិនៃជំពូកទី ៥ នៃច្បាប់នេះ ។

**មាត្រា ៣២.-**

រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ត្រូវចេញប្រកាសអំពីប្រភេទនៃសកម្មភាពអាជីវកម្មទេសចរណ៍ដែលតម្រូវឱ្យមានអាជ្ញាបណ្ណពីក្រសួងទេសចរណ៍ ឬ ពីរដ្ឋបាលថ្នាក់ក្រោមជាតិ ។

គ្មានបុគ្គលណាម្នាក់អាចប្រកបអាជីវកម្មទេសចរណ៍បានទេ ប្រសិនបើបុគ្គលនោះមិនបានទទួលការផ្តល់អាជ្ញាបណ្ណទេសចរណ៍ពីក្រសួងទេសចរណ៍ ឬ ពីរដ្ឋបាលថ្នាក់ក្រោមជាតិ ។ ក្នុងករណីដែលអាជីវកម្មច្រើនប្រភេទត្រូវបានប្រតិបត្តិ ដោយបុគ្គលតែម្នាក់ ចេញពីទីតាំងតែមួយ ប្រភេទអាជីវកម្មនីមួយៗត្រូវតែមានអាជ្ញាបណ្ណផ្សេងៗគ្នា ប្រៀបដូចជាអាជីវកម្មផ្សេងគ្នាដែលប្រតិបត្តិចេញពីទីតាំងផ្សេងគ្នាយ៉ាងដូច្នោះដែរ ។

ក្នុងករណីដែលបុគ្គលម្នាក់មានអាជីវកម្មទេសចរណ៍មួយប្រភេទ ហើយមានសាខាច្រើនកន្លែង សាខានីមួយៗនោះត្រូវតែមានអាជ្ញាបណ្ណទេសចរណ៍ ។

**មាត្រា ៣៣.—**

អាជ្ញាបណ្ណទេសចរណ៍ ដែលចេញដោយក្រសួងទេសចរណ៍ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិ មិនធ្វើឱ្យប្រតិបត្តិករទេសចរណ៍រួចផុតពីកាតព្វកិច្ចក្នុងការចុះបញ្ជីពាណិជ្ជកម្ម ឬ ទទួលការអនុញ្ញាតពីក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធដែលតម្រូវដោយច្បាប់ និងបទប្បញ្ញត្តិជាធរមានឡើយ ។ ក្រសួងទេសចរណ៍សហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធ ដើម្បីបង្កើនប្រសិទ្ធភាពនៃដំណើរការផ្តល់អាជ្ញាបណ្ណទេសចរណ៍ ។

**មាត្រា ៣៤.—**

ក្រសួងទេសចរណ៍ ដោយមានការពិគ្រោះយោបល់ជាមួយផ្នែកឯកជន ក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធត្រូវកំណត់ស្តង់ដារអប្បបរមា និងលក្ខណវិនិច្ឆ័យដទៃទៀតសម្រាប់ប្រភេទនីមួយៗនៃអាជ្ញាបណ្ណទេសចរណ៍ ដែលរៀបចំឡើងដើម្បីបង្កើត កែលម្អ និងរក្សាគុណភាពសេវាកម្មទេសចរណ៍ ។

លក្ខណវិនិច្ឆ័យទាំងនោះត្រូវឱ្យស្របទៅតាមប្រភេទនីមួយៗនៃអាជ្ញាបណ្ណទេសចរណ៍ និងត្រូវមានទំនាក់ទំនងជាមួយកម្មវត្ថុមួយចំនួន ឬ ទាំងអស់ក្នុងចំណោមកម្មវត្ថុទាំងឡាយដូចខាងក្រោម :

ក-សញ្ជាតិ គុណវុឌ្ឍិ បទពិសោធន៍ ចំណេះដឹង និងអត្តចរិតរបស់ប្រតិបត្តិករ និងបុគ្គលិកសំខាន់ៗ ។

ខ-ទីតាំង អគារ បរិក្ខារ ការចុះបញ្ជី និងសមត្ថភាពហិរញ្ញវត្ថុរបស់ប្រតិបត្តិករ ។

លក្ខណវិនិច្ឆ័យសម្រាប់ប្រភេទនៃអាជ្ញាបណ្ណទេសចរណ៍នីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ។

**មាត្រា ៣៥.—**

លក្ខណវិនិច្ឆ័យសម្រាប់ការចេញអាជ្ញាបណ្ណទេសចរណ៍ឱ្យមគ្គុទ្ទេសក៍ទេសចរណ៍ត្រូវមានជាអាទិ៍ដូចខាងក្រោម :

ក-ត្រូវតែជាបុគ្គលដែលមានសញ្ជាតិខ្មែរ និងមានអាយុចាប់ពី ១៨ ឆ្នាំឡើង

ksl

ខ-មានវិញ្ញាបនបត្រជំនាញមគ្គុទ្ទេសក៍ទេសចរណ៍ ដែលការបណ្តុះបណ្តាល ត្រូវបានទទួលស្គាល់ដោយក្រសួងទេសចរណ៍ ។

លក្ខណវិនិច្ឆ័យផ្សេងទៀតដើម្បីផ្តល់អាជ្ញាបណ្ណឱ្យមគ្គុទ្ទេសក៍ទេសចរណ៍ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៣៦.-**

ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ ឬ ពាក្យស្នើសុំបន្តអាជ្ញាបណ្ណទេសចរណ៍ ត្រូវធ្វើឡើងដោយប្រតិបត្តិករទេសចរណ៍ជាសំណុំបែបបទ រួមទាំងឯកសារសម្អាង និង ព័ត៌មានផ្សេងៗទៀត ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ។

ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ត្រូវតែភ្ជាប់មកជាមួយនូវកម្រៃអាជ្ញាបណ្ណ ដែលត្រូវបានកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៣៧.-**

ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍នឹងយកមកធ្វើការវិនិច្ឆ័យ នៅពេលដែលក្រសួងទេសចរណ៍ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិពិនិត្យឃើញថា សាមីជនបានបំពេញត្រឹមត្រូវតាមទម្រង់បែបបទនៃគំរូពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ ។

**មាត្រា ៣៨.-**

ក្រសួងទេសចរណ៍ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវពិនិត្យ និងវាយតម្លៃលើពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ដោយផ្អែកលើព័ត៌មានដែលបានទទួល ឬ សាកសួរបន្ថែមទៀតតាមការចាំបាច់ ។

ក្រសួងទេសចរណ៍ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវជូនដំណឹងទៅអ្នកស្នើសុំអាជ្ញាបណ្ណទេសចរណ៍អំពីសេចក្តីសម្រេចឯកភាពផ្តល់ឱ្យ ឬ មិនឯកភាពផ្តល់ឱ្យក្នុងរយៈពេល ២៨ (ម្ភៃប្រាំបី) ថ្ងៃ ចាប់ពីថ្ងៃបានទទួលពាក្យស្នើសុំពេញលេញ ។ ក្នុងករណីមិនឯកភាពផ្តល់ឱ្យអាជ្ញាបណ្ណទេសចរណ៍ ក្រសួងទេសចរណ៍ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបញ្ជាក់ពីមូលហេតុច្បាស់លាស់ជូនទៅសាមីជន ។

មន្ត្រីក្រសួងទេសចរណ៍ ឬ មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិដែលទទួលខុសត្រូវក្នុងការពិនិត្យ និងវាយតម្លៃពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ ដែលពាក់ព័ន្ធនឹងផលប្រយោជន៍ផ្ទាល់ខ្លួន ពុំអាចឱ្យចូលរួមក្នុងដំណើរការអនុម័តលើពាក្យស្នើសុំនេះទេ ។

**មាត្រា ៣៩.-**

អាជ្ញាបណ្ណដែលបានចេញក្រោមច្បាប់នេះ ត្រូវមានលក្ខខណ្ឌដែលអ្នកទទួល ត្រូវអនុវត្តតាម ។ លក្ខខណ្ឌទាំងនោះ មានដូចតទៅ :

ក-អនុវត្តតាមផែនការ បទដ្ឋានស្ដីពីសំណង់អគារ សុវត្ថិភាពអគ្គិភ័យ សុខភាពម្ហូបអាហារ អនាម័យ កម្លាំងពលកម្ម ពន្ធ ច្បាប់ និង បទប្បញ្ញត្តិដទៃទៀត ដែលទាក់ទងទៅនឹងសកម្មភាព ទីបរិវេណ បរិក្ខារ និយោជិត និងប្រតិបត្តិការអាជីវកម្មទេសចរណ៍ ។

ខ-អនុវត្តតាមស្ដង់ដារ និងការតម្រូវដែលបានចេញដោយក្រសួងទេសចរណ៍ ដូចមានចែងក្នុងមាត្រា ២៣ នៃច្បាប់នេះ ។

គ-អនុវត្តតាមប្រព័ន្ធចំណាត់ថ្នាក់ ដែលបានចេញដោយក្រសួងទេសចរណ៍ ដូចមានចែងក្នុងមាត្រា ២៤ និងមាត្រា ២៥ នៃច្បាប់នេះ ។

ឃ-អនុវត្តតាមវិធានការធានាគុណភាព ដែលចេញដោយក្រសួងទេសចរណ៍ ដូចមានចែងក្នុងមាត្រា ២៨ នៃច្បាប់នេះ និងមិនប្រឌិតព័ត៌មានអំពីស្លាកសញ្ញាពិសេស ស្លាកសញ្ញាបញ្ជាក់គុណភាព ការទទួលស្គាល់គុណភាព រង្វាន់ ឬ ការលើកទឹកចិត្តដែលអាជីវកម្មនោះ មិនមានត្រឹមត្រូវនោះឡើយ ។

ង-ប្រសិនបើអាជីវកម្មទេសចរណ៍ត្រូវបានផ្ដល់ឱ្យមានចំណាត់ថ្នាក់កម្រិតណាមួយដូចបានចែងនៅក្នុងមាត្រា ២៤ និងមាត្រា ២៥ នៃច្បាប់នេះ ចំណាត់ថ្នាក់នោះ ត្រូវតែដាក់តាំងនៅកន្លែងដែលងាយមើលឃើញក្នុងទីតាំងអាជីវកម្មរបស់ម្ចាស់អាជ្ញាបណ្ណ ហើយត្រូវតែបញ្ជាក់នូវគ្រប់ការធ្វើការងាររកទីផ្សារ ការផ្សាយពាណិជ្ជកម្ម និងការសរសេរផ្សេងៗ ។

ច-អនុវត្តតាមក្រមប្រតិបត្តិវិជ្ជាជីវៈ និងក្រមសីលធម៌វិជ្ជាជីវៈ ដែលចេញដោយក្រសួងទេសចរណ៍ ឬ ដោយសមាគមឧស្សាហកម្មទេសចរណ៍ ដែលមានការយល់ព្រមពីក្រសួងទេសចរណ៍ សម្រាប់អាជីវកម្មទេសចរណ៍ប្រភេទនោះ ។

ឆ-ផ្តល់ព័ត៌មានជាលាយលក្ខណ៍អក្សរដល់ក្រសួងទេសចរណ៍ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងរយៈពេល ១៤ (ដប់បួន) ថ្ងៃ ក្រោយពីមានការផ្លាស់ប្តូរចំណុចពិស្តារណាមួយដែលទាក់ទងទៅនឹងអាជីវកម្មរបស់ម្ចាស់អាជ្ញាបណ្ណ ។

ជ-ផ្តល់ជូនក្រសួងទេសចរណ៍ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យបានទាន់ពេលវេលា ស្ថិតិ និងព័ត៌មានផ្សេងៗដែលទាក់ទងនឹងអាជីវកម្មទេសចរណ៍ តាមការស្នើសុំ និងការតម្រូវដោយក្រសួងទេសចរណ៍ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិ ។

ឈ-ដាក់តាំងអាជ្ញាបណ្ណទេសចរណ៍ នៅទីកន្លែងដែលងាយមើលឃើញច្បាស់ក្នុងទីបរិវេណធ្វើអាជីវកម្មរបស់អ្នកទទួលអាជ្ញាបណ្ណ ។

ញ-ធានាថាលេខចុះបញ្ជី និងប្រភេទអាជ្ញាបណ្ណទេសចរណ៍ត្រូវបញ្ជាក់ រាល់ពេលសរសេរឆ្លើយឆ្លងជាមួយបណ្តាដៃគូពាក់ព័ន្ធ និងដៃគូអាជីវកម្ម ។

ចំពោះលក្ខខណ្ឌពិសេសផ្សេងៗទៀត ដែលតម្រូវសម្រាប់ប្រភេទអាជ្ញាបណ្ណនីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ។

**មាត្រា ៤០.-**

ភ្នាក់ងារទេសចរណ៍ និងការីទេសចរណ៍ ដើម្បីធានាដល់អាជីវកម្ម និង ការពារអតិថិជនត្រូវកក់ប្រាក់ធានាក្នុងធនាគារជាសាច់ប្រាក់ ឬ ជាការធានារបស់ធនាគារ តាមទំហំមួយដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ។

នីតិវិធី និងសេចក្តីតម្រូវលើការគ្រប់គ្រងប្រាក់កក់ធានា និងការផ្លាស់ប្តូរនៃប្រាក់កក់ធានាក្នុងធនាគារ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ។

**មាត្រា ៤១.-**

ប្រសិនបើ អ្នកស្នើសុំឆ្លើយតបទៅនឹងលក្ខណវិនិច្ឆ័យ និងការតម្រូវដូចមានចែងក្នុងជំពូកទី ៥ នៃច្បាប់នេះ ក្រសួងទេសចរណ៍ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវចេញអាជ្ញាបណ្ណដែលមានសុពលភាពអប្បបរមា ០១ (មួយ) ឆ្នាំ ដល់អ្នកស្នើសុំ ។

ប្រសិនបើ អ្នកស្នើសុំពុំបានបំពេញទៅតាមលក្ខខណ្ឌ ដូចមានចែងក្នុងជំពូកទី ៥ នៃច្បាប់នេះ ហើយបើក្រសួងទេសចរណ៍ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិ យល់ព្រមទទួលយកនូវការធានាជាលាយលក្ខណ៍អក្សរពីអ្នកស្នើសុំក្នុងការអនុវត្ត តាមលក្ខណវិនិច្ឆ័យ និងសេចក្តី

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

Ksl

តម្រូវនោះ ក្រសួងទេសចរណ៍ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិ អាចចេញនូវអាជ្ញាបណ្ណបណ្ដោះអាសន្នដែលមានសុពលភាពរយៈពេល ៩០ (កៅសិប) ថ្ងៃ ក្រោយពេលដែលអ្នកស្នើសុំបានបង់កម្រៃអាជ្ញាបណ្ណរួច ។

ក្នុងរយៈពេលកំណត់នៃកិច្ចសន្យា បើពិនិត្យឃើញថា ម្ចាស់អាជ្ញាបណ្ណបណ្ដោះអាសន្នបានអនុវត្តទៅតាមលក្ខណវិនិច្ឆ័យ និងការតម្រូវទាំងអស់រួចហើយ ក្រសួងទេសចរណ៍ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវសម្រេចផ្ដល់ឱ្យនូវអាជ្ញាបណ្ណពេញសិទ្ធិដល់អ្នកស្នើសុំ ។ ផ្ទុយទៅវិញ ក្នុងករណីដែលអ្នកស្នើសុំមិនបានបំពេញតាមលក្ខខណ្ឌនៃកិច្ចសន្យា ហើយនៅតែបន្តធ្វើអាជីវកម្មលើអាជ្ញាបណ្ណបណ្ដោះអាសន្នដែលអស់សុពលភាព ត្រូវចាត់ទុកថាជាការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ ។

**មាត្រា ៤២.-**

ម្ចាស់អាជ្ញាបណ្ណ ត្រូវតែដាក់ពាក្យសុំបន្តអាជ្ញាបណ្ណឱ្យបាន ៣០ (សាមសិប) ថ្ងៃ យ៉ាងតិចមុនថ្ងៃផុតកំណត់សុពលភាពអាជ្ញាបណ្ណ ដោយភ្ជាប់មកជាមួយនូវប្រាក់កម្រៃអាជ្ញាបណ្ណ ព្រមទាំងឯកសារ និងព័ត៌មានផ្សេងៗដែលបានកំណត់នៅក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ។

**មាត្រា ៤៣.-**

អាជ្ញាបណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ដែលចេញនៅក្រោមច្បាប់នេះ មិនអាចធ្វើការផ្ទេរ ឬ លក់បានទេ ដោយសារតែអាជ្ញាបណ្ណនេះផ្អែកលើគុណវុឌ្ឍិបុគ្គល និង បទពិសោធន៍របស់ម្ចាស់អាជ្ញាបណ្ណ ។

អាជ្ញាបណ្ណទេសចរណ៍ដទៃផ្សេងទៀតដែលចេញនៅក្រោមច្បាប់នេះអាចផ្ទេរ ឬ លក់ក្រោមលក្ខខណ្ឌដូចតទៅ :

ក-ម្ចាស់អាជ្ញាបណ្ណត្រូវដាក់ពាក្យសុំផ្ទេរ ឬ លក់អាជ្ញាបណ្ណមកក្រសួងទេសចរណ៍ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិ តាមគំរូដែលបានកំណត់ និងដោយភ្ជាប់មកជាមួយនូវសោហ៊ុយសេវាផ្ទេរ ឬ លក់អាជ្ញាបណ្ណ ឯកសាររួមទាំងព័ត៌មានផ្សេងៗទៀតដែលកំណត់ដោយក្រសួងទេសចរណ៍ ។

ខ-បុគ្គលជាអ្នកទទួលអាជ្ញាបណ្ណពីការផ្ទេរ ឬទិញអាជ្ញាបណ្ណត្រូវបំពេញរាល់លក្ខខណ្ឌតម្រូវស្ដីពីការចេញអាជ្ញាបណ្ណរបស់ក្រសួងទេសចរណ៍ ដូចមានចែងក្នុងជំពូកទី ៥ នៃច្បាប់នេះ ។

គ-ការផ្ទេរ ឬ ការលក់អាជ្ញាបណ្ណទេសចរណ៍នេះអាចប្រព្រឹត្តទៅបាន លុះត្រាណាតែម្ចាស់អាជ្ញាបណ្ណបានបំពេញកាតព្វកិច្ចពន្ធ តាមច្បាប់ជាធរមាន និងបានដោះស្រាយរួចរាល់នូវបញ្ហាផ្សេងៗទៀត ជាមួយបណ្ដាភាគីពាក់ព័ន្ធរបស់ខ្លួន ឬ បុគ្គលជាអ្នកទទួលអាជ្ញាបណ្ណពីការផ្ទេរ ឬ ការទិញអាជ្ញាបណ្ណ យល់ព្រមជាលាយលក្ខណ៍អក្សរបំពេញកាតព្វកិច្ចពន្ធ ឬ ដោះស្រាយបញ្ហាសេសសល់ទាំងនោះ លើកលែងតែមានកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរផ្សេងពីនេះ រវាងភាគីពាក់ព័ន្ធ ។

ឃ-ក្នុងករណីដែលអាជ្ញាបណ្ណជាអាជ្ញាបណ្ណបណ្ដោះអាសន្ន បុគ្គលជាអ្នកទទួលអាជ្ញាបណ្ណពីការផ្ទេរ ឬ ការទិញអាជ្ញាបណ្ណ ត្រូវផ្ដល់ជូនក្រសួងទេសចរណ៍ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិនូវការយល់ព្រមជាលាយលក្ខណ៍អក្សរនៅក្នុងការបំពេញលក្ខខណ្ឌដែលនៅសល់ក្នុងរយៈពេលនៅសល់ ។

**មាត្រា ៥៥.-**

ប្រសិនបើក្រសួងទេសចរណ៍ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិរកឃើញថា ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ បានផ្ដល់ព័ត៌មានមិនពិតទាក់ទងទៅនឹងការដាក់ពាក្យសុំ ឬ ខកខានក្នុងការអនុវត្តតាមលក្ខខណ្ឌទាំងអស់ ឬ លក្ខខណ្ឌណាមួយនៃអាជ្ញាបណ្ណ ក្រសួងទេសចរណ៍ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិអាចលុបចោលអាជ្ញាបណ្ណ ព្យួរអាជ្ញាបណ្ណ ឬ បញ្ចុះថ្នាក់អាជ្ញាបណ្ណនោះទៅជាអាជ្ញាបណ្ណបណ្ដោះអាសន្ន ដោយធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរ ៣០ (សាមសិប) ថ្ងៃ ជាមុនទៅកាន់ម្ចាស់អាជ្ញាបណ្ណ ។ សេចក្ដីជូនដំណឹងអំពីការលុប ការព្យួរ ឬ ការបញ្ចុះថ្នាក់អាជ្ញាបណ្ណទេសចរណ៍នេះ ត្រូវមានបញ្ជាក់ហេតុផលច្បាស់លាស់ ។

នៅក្នុងស្ថានភាពបន្ទាន់ដែលក្រសួងទេសចរណ៍ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិពិនិត្យឃើញថា ការបន្តប្រតិបត្តិការអាជីវកម្មទេសចរណ៍មួយ បង្កឱ្យមានហានិភ័យធ្ងន់ធ្ងរភ្លាមៗមកលើសុខុមាលភាព សុវត្ថិភាព ឬ សន្តិសុខ ក្រសួងទេសចរណ៍ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិអាចលុប ឬ ព្យួរអាជ្ញាបណ្ណនោះជាបន្ទាន់ ដោយបញ្ជាក់ហេតុផលច្បាស់លាស់ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

ការលុបចោល ការព្យួរ ឬ ការបញ្ចុះថ្នាក់អាជ្ញាបណ្ណ ដូចមានចែងក្នុងមាត្រានេះ មិនធ្វើឱ្យម្ចាស់អាជ្ញាបណ្ណរួចផុតពីការទទួលខុសត្រូវចំពោះបទល្មើស និង ទោសប្បញ្ញត្តិ ដែលមានកំណត់ក្នុងជំពូកទី ១០ នៃច្បាប់នេះ និងច្បាប់ជាធរមានដទៃទៀតឡើយ ។

លក្ខខណ្ឌ និងនីតិវិធីនៃការលុប ការព្យួរ ឬ ការបញ្ចុះថ្នាក់អាជ្ញាបណ្ណទេសចរណ៍ មកជាអាជ្ញាបណ្ណបណ្ដោះអាសន្ន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ។

**មាត្រា ៤៥.-**

ក្នុងករណី ដែលម្ចាស់អាជ្ញាបណ្ណទេសចរណ៍មិនបំពេញទៅតាមលក្ខណវិនិច្ឆ័យ ឬ ការតម្រូវផ្សេងៗ សម្រាប់អាជ្ញាបណ្ណដោយសារតែហេតុផលមរណភាពរបស់ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ ឬ របស់អ្នកចាត់ការ ឬ ដោយហេតុផលស្របច្បាប់ដែលហួសពីការត្រួតត្រារបស់ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ និងមានលក្ខណៈអាចទទួលយកបាន ក្រសួងទេសចរណ៍ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិអាចផ្ដល់អាជ្ញាបណ្ណទេសចរណ៍បណ្ដោះអាសន្នដល់ម្ចាស់អាជ្ញាបណ្ណទេសចរណ៍ ទាយាទ ឬ បុគ្គលដែលមានការទទួលខុសត្រូវ នៅក្នុងការរំលាយក្រុមហ៊ុន ដើម្បីសម្រួល កែតម្រូវបញ្ហាតាមលំដាប់លំដោយ ឬ ដើម្បីផ្ទេរអាជីវកម្មនោះ ។

**មាត្រា ៤៦.-**

បុគ្គលណាម្នាក់ដែលគិតថា បានទទួលរងគ្រោះដោយសារសេចក្ដីសម្រេចរបស់ក្រសួងទេសចរណ៍ ឬ របស់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីការបដិសេធ ការព្យួរ ការលុប ការបញ្ចុះថ្នាក់ ឬ ការសម្រេចដែលមានការពាក់ព័ន្ធផ្សេងៗដូចមានចែងក្នុងជំពូកទី ៥ នៃច្បាប់នេះ អាចធ្វើលិខិតតវ៉ាទៅរដ្ឋមន្ត្រីក្រសួងទេសចរណ៍ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃបន្ទាប់ពីបានទទួលសេចក្ដីជូនដំណឹងជាលាយលក្ខណ៍អក្សរស្ដីពីការសម្រេចណាមួយ ដូចរៀបរាប់ខាងលើ ។

បន្ទាប់ពីបានទទួលលិខិតតវ៉ា ក្រសួងទេសចរណ៍ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិ អាចធ្វើការព្យួរសេចក្ដីសម្រេចរបស់ខ្លួន ហើយធ្វើការសម្រេចជាថ្មីឡើងវិញ ក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ ។

ROYAUME DU CAMBODGE * MINISTRE DU PALAIS ROYAL

**មាត្រា ៤៧.-**

ក្រសួងទេសចរណ៍ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរក្សាបញ្ជីអាជ្ញាបណ្ណទេសចរណ៍ ត្រូវបោះពុម្ពរាល់សេចក្តីសម្រេច រួមទាំងការបដិសេធ ការផ្តល់ឱ្យ ការលុបចោល ការព្យួរ ការបញ្ចុះថ្នាក់នៃអាជ្ញាបណ្ណទេសចរណ៍នៅក្នុងព្រឹត្តិបត្រ និង/ឬគេហទំព័ររបស់ខ្លួន ។

សាធារណជនអាចសុំពិនិត្យមើលបញ្ជីអាជ្ញាបណ្ណទេសចរណ៍ នៅក្រសួងទេសចរណ ឬ ទីស្នាក់ការរដ្ឋបាលថ្នាក់ក្រោមជាតិបានគ្រប់ពេលម៉ោងធ្វើការ និងអាចស្នើសុំថតចម្លងឯកសារនោះបាន ។

## ជំពូកទី ៦
## ភារកិច្ចរបស់ភាគីពាក់ព័ន្ធលើវិស័យទេសចរណ៍

**មាត្រា ៤៨.-**

ប្រតិបត្តិករទេសចរណ៍ រួមទាំងភ្នាក់ងារ និយោជិត និងអ្នកជាប់កិច្ចសន្យាទាំងអស់ ត្រូវមានកាតព្វកិច្ចដូចតទៅ :

ក-អនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ដែលពាក់ព័ន្ធនឹងស្តង់ដារ ក្រមប្រតិបត្តិវិជ្ជាជីវៈ ក្រមសីលធម៌វិជ្ជាជីវៈ និងលក្ខខណ្ឌនានានៃអាជ្ញាបណ្ណទេសចរណ៍ ។

ខ-អនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិទាំងឡាយ ដែលប៉ះពាល់ទៅលើ ឬ ទទួលរងការប៉ះពាល់ដោយវិស័យទេសចរណ៍ ដូចជាការកំណត់នគរូបនីយកម្ម ការសាងសង់អគារ សុវត្ថិភាព អគ្គិភ័យ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ បរិស្ថាន សុខភាព អនាម័យ ម្ហូបអាហារ ការងារ កាតព្វកិច្ចពន្ធ គណនេយ្យ និងហិរញ្ញវត្ថុ ការការពារ មរតកវប្បធម៌ មរតកធម្មជាតិ និងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

គ-ការពារប្រយោជន៍ជាតិ និងប្រយោជន៍ទេសចរ និងចូលរួមចំណែកនៅក្នុងការថែរក្សាធនធានធម្មជាតិ មិនបំពុល ឬ មិនបំផ្លាញបរិស្ថាន ការពារនិងអភិរក្សមរតកវប្បធម៌ សិល្បៈ ប្រពៃណី ទំនៀមទម្លាប់ របស់ប្រជាពលរដ្ឋខ្មែរក្នុងរាល់សកម្មភាពទេសចរណ៍របស់ខ្លួន ។

ឃ-ផ្តល់ដល់ទេសចរនូវព័ត៌មានពិតច្បាស់លាស់ និងទទួលខុសត្រូវផ្តល់សេវាកម្ម

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL · ក្រសួងព្រះបរមរាជវាំង

kl

ដូចដែលបានសន្យា ព្រមទាំងមានវិធានការសមស្របដើម្បីថែទាំទ្រព្យសម្បត្តិ ការពារសន្តិសុខ និងសុវត្ថិភាពដល់ទេសចរក្នុងពេលដែលទេសចរស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន ។

ង-ប្តឹង ឬ រាយការណ៍ជាបន្ទាន់ទៅនគរបាលទេសចរណ៍ អាជ្ញាធរមានសមត្ថកិច្ច ឬ សមត្ថកិច្ចទេសចរណ៍ដែលនៅជិតបំផុត ក្នុងករណីដឹង ឬ មានការសង្ស័យថា មានការប្រព្រឹត្តបទល្មើស ការជួញដូរ និង ការប្រើប្រាស់គ្រឿងញៀន ការជួញដូរនិងការបង្ខាំងមនុស្ស ការជួញដូរកុមារ ការធ្វើអាជីវកម្មផ្លូវភេទ ការផ្សព្វផ្សាយរូបភាព និង សម្ភារៈអាសអាភាស ឬ ប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌផ្សេងៗទៀត ។

ច-អ្នកគ្រប់គ្រងសណ្ឋាគារ ឬ សេវាកម្មស្នាក់នៅទេសចរណ៍ ត្រូវកត់ត្រាទុកអត្តសញ្ញាណរបស់អតិថិជន និងព័ត៌មានផ្សេងៗទៀតនៅពេលចូលស្នាក់នៅ ។

ឆ-សហការនៅក្នុងកិច្ចការអធិការកិច្ច ដូចមានចែងក្នុងមាត្រា ៦០ នៃច្បាប់នេះ ។

ជ-ប្រតិបត្តិស្របតាមក្រមសីលធម៌វិជ្ជាជីវៈរបស់អង្គការទេសចរណ៍ពិភពលោកឱ្យបានល្អ ។

ឈ-អនុវត្តឱ្យបានខ្ជាប់ខ្ជួននូវលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៣៩ និងលក្ខខណ្ឌដទៃផ្សេងទៀតដែលមានចែងក្នុងជំពូកទី ៥ នៃច្បាប់នេះ ។

**មាត្រា ៤៩.-**

មន្ត្រីមានសមត្ថកិច្ចដែលពាក់ព័ន្ធនឹងវិស័យទេសចរណ៍ ត្រូវមានកាតព្វកិច្ច ដូចតទៅ :

ក-ផ្តល់ដល់ទេសចរនូវព័ត៌មានឥតលាក់លៀម និងមិនលំអៀង ។

ខ-ជួយយកអាសាដោយភាពស្មោះត្រង់ និងផ្តល់ភាពរាក់ទាក់ក្នុងនាមជាម្ចាស់ផ្ទះ ។

គ-សម្រួលការធ្វើដំណើរដល់ទេសចរ សម្រួលកិច្ចការលិខិតស្នាម និង បែបបទនានាឱ្យសាមញ្ញ ។

ឃ-មិនរើសអើងសញ្ជាតិ ពូជសាសន៍ ពណ៌សម្បុរ និងសាសនា ។

ង-ចាត់វិធានការចាំបាច់ ដើម្បីការពារថែរក្សាទ្រព្យសម្បត្តិរបស់ទេសចរ និងសន្តិសុខ សុវត្ថិភាព ។

ច-ប្រតិបត្តិស្របតាមក្រមសីលធម៌វិជ្ជាជីវៈរបស់អង្គការទេសចរណ៍ពិភពលោកឱ្យ បានល្អ ។

## មាត្រា ៥០.-

ទេសចរ ឬ អ្នកធ្វើដំណើរកម្សាន្តត្រូវមានកាតព្វកិច្ចដូចតទៅ :

ក-គោរពច្បាប់ និងបទប្បញ្ញត្តិជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជា ។

ខ-គោរពប្រពៃណី ទំនៀមទម្លាប់ និងវប្បធម៌ខ្មែរ និងមិនត្រូវចូលរួមក្នុងសកម្មភាពណាមួយដែលបំពាន ឬ ធ្វើឱ្យខូចដល់វប្បធម៌ខ្មែរ ។

គ-មិនត្រូវធ្វើឱ្យខូចខាតដល់បរិស្ថាន ឬ មរតកវប្បធម៌ និងមរតកធម្មជាតិ ។

ឃ-មិនត្រូវចូលរួមក្នុងសកម្មភាពណាមួយដែលពាក់ព័ន្ធដល់ការជួញដូរ និងការប្រើប្រាស់គ្រឿងញៀន ការជួញដូរនិងការបង្ខាំងមនុស្ស ការជួញដូរកុមារ ការធ្វើអាជីវកម្មផ្លូវភេទ ការផ្សព្វផ្សាយរូបភាព និង សម្ភារៈអាសអាភាស ការលាងលុយកខ្វក់ និងការបង្កឱ្យមានអសន្តិសុខក្នុងសង្គម ។

ង-មិនធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គម និងសុខុមាលភាពជាទូទៅ ។

ច-មិនត្រូវគំរាមកំហែងដល់សន្តិសុខ ឬ ជាប់ពាក់ព័ន្ធដល់ក្រុមភេរវកម្ម ។

ឆ-អនុវត្តឱ្យ បានខ្ជាប់ខ្ជួននូវក្រមប្រតិបត្តិវិជ្ជាជីវៈ និងក្រមសីលធម៌វិជ្ជាជីវៈដែលចេញដោយក្រសួងទេសចរណ៍ ឬ ដែលបង្កើតឡើងដោយសមាគមឧស្សាហកម្មទេសចរណ៍ ហើយយល់ព្រមដោយក្រសួងទេសចរណ៍ ។

ជ-ប្រតិបត្តិស្របតាមក្រមសីលធម៌វិជ្ជាជីវៈរបស់អង្គការទេសចរណ៍ពិភពលោកឱ្យ បានល្អ ។

ឈ-ចំពោះទេសចរ ឬ អ្នកធ្វើដំណើរកម្សាន្តជាជនបរទេសមិនត្រូវប្រើប្រាស់ទិសដៅទេសចរណ៍ ជាឱកាសដើម្បីស្វែងរកការងារ ឬ ការតាំងលំនៅឋាន ។

## មាត្រា ៥១.-

ក្រសួងទេសចរណ៍ត្រូវរៀបចំបង្កើត និងបំផុសឱ្យ មានការបង្កើតក្រមប្រតិបត្តិវិជ្ជាជីវៈ និងក្រមសីលធម៌វិជ្ជាជីវៈ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរ អ្នកពាក់ព័ន្ធ សមាគម ឧស្សាហកម្មទេសចរណ៍ និងអ្នកដែលពាក់ព័ន្ធផ្សេងៗទៀត ។

**មាត្រា ៥២.-**

ក្រសួងទេសចរណ៍អាចផ្ទេរការទទួលខុសត្រូវ ចំពោះការបង្កើតក្រមប្រតិបត្តិវិជ្ជាជីវៈ និងក្រមសីលធម៌វិជ្ជាជីវៈ ទៅឱ្យសមាគមឧស្សាហកម្មទេសចរណ៍ដែលពាក់ព័ន្ធ នៅពេលដែលសមាគមឧស្សាហកម្មទេសចរណ៍នោះ ត្រូវបានបង្កើតឡើងដោយមានតំណាងគ្រប់គ្រាន់ និងមានប្រសិទ្ធភាព ។ ប្រសិនបើក្រសួងទេសចរណ៍ស្នើឱ្យសមាគមឧស្សាហកម្មទេសចរណ៍បង្កើត ឬ ធ្វើឱ្យប្រសើរនូវក្រមប្រតិបត្តិវិជ្ជាជីវៈ និងក្រមសីលធម៌វិជ្ជាជីវៈ សមាគមឧស្សាហកម្មទេសចរណ៍ត្រូវទទួលធ្វើការងារនេះ ដោយពិគ្រោះយោបល់ជាមួយសមាជិករបស់ខ្លួន និងអ្នកពាក់ព័ន្ធផ្សេងៗទៀត ហើយដាក់ឆ្លងសេចក្តីព្រាងក្រមប្រតិបត្តិវិជ្ជាជីវៈ និងក្រមសីលធម៌វិជ្ជាជីវៈនោះទៅក្រសួងទេសចរណ៍ ដើម្បីពិនិត្យ និងសម្រេច ។

**មាត្រា ៥៣.-**

ក្រមប្រតិបត្តិវិជ្ជាជីវៈ និងក្រមសីលធម៌វិជ្ជាជីវៈដែលចេញដោយក្រសួងទេសចរណ៍ ត្រូវភ្ជាប់កាតព្វកិច្ចលើអ្នកដែលពាក់ព័ន្ធ ហើយអាចប្រើជាលក្ខខណ្ឌសម្រាប់ការចេញទិដ្ឋាការទេសចរណ៍តាមការស្នើសុំរបស់ក្រសួងទេសចរណ៍ ។

ក្រមប្រតិបត្តិវិជ្ជាជីវៈ និងក្រមសីលធម៌វិជ្ជាជីវៈដែលបានបង្កើតឡើងដោយសមាគមឧស្សាហកម្មទេសចរណ៍ និងយល់ព្រមដោយក្រសួងទេសចរណ៍ ត្រូវភ្ជាប់កាតព្វកិច្ចលើសមាជិករបស់ខ្លួន ហើយសមាគមត្រូវចាត់វិធានការសមស្រប ដើម្បីធានាឱ្យសមាជិករបស់ខ្លួនអនុវត្តតាម ។

## ជំពូកទី ៧
## ការដោះស្រាយវិវាទទេសចរណ៍

**មាត្រា ៥៤.-**

ក្រសួងទេសចរណ៍ត្រូវរៀបចំបង្កើតគណៈកម្មការមួយហៅថា "**គណៈកម្មការដោះស្រាយវិវាទទេសចរណ៍**" ដើម្បីសម្របសម្រួល ដោះស្រាយវិវាទ និង ការប្រតិបត្តិតាមកាតព្វកិច្ចក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ ។

រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ត្រូវចេញប្រកាសដើម្បីផ្សព្វផ្សាយអំពីប្រភេទនៃវិវាទនានា ដែលក្រសួងមានតួនាទីជាអ្នកទទួលដោះស្រាយ ។

**មាត្រា ៥៥.-**

ប្រភេទវិវាទដែលក្រសួងទេសចរណ៍ មានតួនាទីជាអ្នកទទួលសម្របសម្រួល និង ដោះស្រាយ រួមមានវិវាទរវាងប្រតិបត្តិករអាជីវកម្មទេសចរណ៍ ភ្នាក់ងាររបស់គេ និយោជិត អ្នកជាប់កិច្ចសន្យា មន្ត្រីសមត្ថកិច្ចដែលពាក់ព័ន្ធនឹងទេសចរណ៍ ទេសចរ និងអ្នកពាក់ព័ន្ធផ្សេងៗទៀត ។

គណៈកម្មការដោះស្រាយវិវាទទេសចរណ៍ ត្រូវពិចារណាដោះស្រាយវិវាទប្រកបដោយយុត្តិធម៌ ។ ប្រសិនបើគណៈកម្មការមិនអាចដោះស្រាយវិវាទនោះបានទេ ភាគីណាមួយអាចបន្តរឿងក្តីនោះទៅតុលាការដើម្បីរកដំណោះស្រាយតាមផ្លូវច្បាប់ ។

ការចំណាយ និងសោហ៊ុយរបស់គណៈកម្មការដោះស្រាយវិវាទទេសចរណ៍ ត្រូវកំណត់ដោយប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ៨
## ការហាមប្រាមអនីតិជន

**មាត្រា ៥៦.-**

អនីតិជនមិនត្រូវបានអនុញ្ញាត ឱ្យចូលទៅកាន់ទីបរិវេណមណ្ឌលកម្សាន្តទេសចរណ៍សម្រាប់មនុស្សពេញវ័យឡើយ ។

**មាត្រា ៥៧.-**

អ្នកគ្រប់គ្រង និងម្ចាស់អាជ្ញាបណ្ណនៃមណ្ឌលកម្សាន្តទេសចរណ៍សម្រាប់មនុស្សពេញវ័យត្រូវហាមឃាត់ និងចាត់វិធានការសមស្របដើម្បីធានាថា មិនមានវត្តមានអនីតិជននៅក្នុងទីបរិវេណនោះ និងត្រូវត្រួតពិនិត្យផ្ទៀងផ្ទាត់អត្តសញ្ញាណបណ្ណអតិថិជនវ័យក្មេងទាំងអស់ដើម្បីធានាឱ្យមានការប្រតិបត្តិតាមកាតព្វកិច្ចក្រោមមាត្រានេះ ។

បែបបទនៃការអនុវត្តមាត្រា ៥៦ និងមាត្រា ៥៧ នៃច្បាប់នេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី ៩
## ការអង្កេត អធិការកិច្ច និងការអនុវត្តច្បាប់

**មាត្រា ៥៨.-**

ក្រសួងទេសចរណ៍ត្រូវដឹកនាំការងារអធិការកិច្ច ៖

ក-បញ្ជូនមន្ត្រីចុះត្រួតពិនិត្យ ធ្វើអធិការកិច្ចលើទីកន្លែងប្រកបអាជីវកម្ម លើទីបរិវេណ ឬ សម្ភារៈដែលបានប្រើប្រាស់ ឬ សង្ស័យថាបានប្រើប្រាស់សម្រាប់គោលបំណងអាជីវកម្មទេសចរណ៍ និងដែលបានប្រើប្រាស់ ឬ ដែលបានសង្ស័យថាបានប្រើប្រាស់ផ្ទុយនឹងច្បាប់ ។ ក្នុងការធ្វើអធិការកិច្ច ក្រសួងទេសចរណ៍អាចសហការ និងសម្របសម្រួលជាមួយមន្ត្រីពីក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចផ្សេងៗទៀត ។

ខ-ប្រសិនបើទីបរិវេណប្រកបអាជីវកម្មនោះ ត្រូវបានប្រើប្រាស់ជាលំនៅឋានផងដែរ ការធ្វើអធិការកិច្ចអាចប្រព្រឹត្តទៅបានតែក្នុងអំឡុងម៉ោងអាជីវកម្មប៉ុណ្ណោះ ។

**មាត្រា ៥៩.-**

មន្ត្រីអធិការកិច្ចត្រូវបង្ហាញអត្តសញ្ញាណបណ្ណមុខងារ និងបណ្ណបេសកកម្ម ឬ លិខិតអនុញ្ញាតឱ្យបំពេញបេសកកម្មមុនចាប់ផ្តើមធ្វើអធិការកិច្ច ។មន្ត្រីអធិការកិច្ចទេសចរណ៍ត្រូវមាននីតិសម្បទាជានគរបាលយុត្តិធម៌ ។

**មាត្រា ៦០.-**

ម្ចាស់អាជ្ញាបណ្ណ ប្រតិបត្តិករទេសចរណ៍ និងបុគ្គលដែលកាន់កាប់ទីកន្លែងប្រកបអាជីវកម្ម ទីបរិវេណ ឬ សម្ភារៈបរិក្ខារជាកម្មវត្ថុនៃអធិការកិច្ច ត្រូវសហការជាមួយមន្ត្រីអធិការកិច្ចទេសចរណ៍ដោយផ្តល់ព័ត៌មានត្រឹមត្រូវពិតប្រាកដ គ្រប់គ្រាន់ និងការពន្យល់បកស្រាយរាល់ការចោទសួរណាមួយ ដើម្បីធានាឱ្យមន្ត្រីអធិការកិច្ច អាចអនុវត្តភារកិច្ចបាន ។ គ្មានបុគ្គលណាម្នាក់អាចរារាំង បង្អាក់ ឬ ជ្រៀតជ្រែកក្នុងការងារអធិការកិច្ចដែលមានចែងក្នុងច្បាប់នេះឡើយ ។

**មាត្រា ៦១.–**

ប្រសិនបើមន្ត្រីអធិការកិច្ចពិនិត្យឃើញថាមានការរំលោភបទប្បញ្ញត្តិនៃច្បាប់នេះ មន្ត្រីអធិការកិច្ចនោះអាចចាត់វិធានការតាមច្បាប់នេះ និងក្នុងករណីចាំបាច់ ត្រូវស្នើសុំឱ្យមានកិច្ចសហការពីសមត្ថកិច្ចពាក់ព័ន្ធ ។ បើជាករណីធ្ងន់ធ្ងរត្រូវរាយការណ៍ ជាបន្ទាន់ជូនក្រសួងទេសចរណ៍ដើម្បីចាត់វិធានការតាមច្បាប់ ។

ក្នុងករណីដែលពិនិត្យឃើញ ឬ មានហេតុផលជាមូលដ្ឋានអាចជឿជាក់ថាមានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ មន្ត្រីអធិការកិច្ចនោះត្រូវរាយការណ៍ជាបន្ទាន់ជូនព្រះរាជអាជ្ញា ឬ មន្ត្រីនគរបាលយុត្តិធម៌មានសមត្ថកិច្ចនៃតំបន់ពាក់ព័ន្ធនោះ ដើម្បីចាត់វិធានការតាមនីតិវិធីនៃច្បាប់ ។

**មាត្រា ៦២.–**

ក្រសួងទេសចរណ៍ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិចាត់វិធានការចាំបាច់ ដើម្បីបញ្ឈប់ជាបន្ទាន់ និងបិទអាជីវកម្មណាដែលអាជ្ញាបណ្ណរបស់អាជីវកម្មនោះ ត្រូវបានលុបចោល ឬ ព្យួរ ឬ អាជីវកម្មណាដែលគ្មានអាជ្ញាបណ្ណទេសចរណ៍ ។

## ជំពូកទី ១០

## ទោសប្បញ្ញត្តិ

**មាត្រា ៦៣.–**

ការពិន័យអន្តរការណ៍ ដែលកំណត់ដោយច្បាប់នេះ ត្រូវធ្វើដោយមន្ត្រីអធិការកិច្ចទេសចរណ៍ និង/ឬនគរបាលទេសចរណ៍ ។ នីតិវិធី និងលក្ខខណ្ឌក្នុងការពិន័យអន្តរការណ៍ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ។

ការបែងចែកសមត្ថកិច្ចរវាងមន្ត្រីអធិការកិច្ចទេសចរណ៍ និងនគរបាលទេសចរណ៍ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា ៦៤.–**

ការដាក់ពិន័យអន្តរការណ៍ មិនធ្វើឱ្យអ្នកប្រព្រឹត្តអំពើនោះរួចផុតពីការទទួលខុសត្រូវខាងរដ្ឋប្បវេណី និង/ឬការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ដែលមានចែងដោយច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

**មាត្រា ៦៥.–**

បុគ្គលណាដែលប្រកបអាជីវកម្មទេសចរណ៍ដោយគ្មានអាជ្ញាបណ្ណទេសចរណ៍ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ ដែលអប្បបរមាស្មើនឹង ២.០០០.០០០ (ពីរលាន) រៀល និងអតិបរមាមិនលើសពី ២០.០០០.០០០ (ម្ភៃលាន) រៀល ។ ទំហំទឹកប្រាក់នៃការពិន័យអន្តរការណ៍សម្រាប់ប្រភេទអាជីវកម្មទេសចរណ៍នីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ។

**មាត្រា ៦៦.–**

ការប្រព្រឹត្តរំលោភលើកាតព្វកិច្ច ដូចមានចែងក្នុងមាត្រា ៤៨ នៃច្បាប់នេះ អាចជាកម្មវត្ថុនៃការពិន័យអន្តរការណ៍ ។ អំពើដែលជាកម្មវត្ថុ និងទំហំទឹកប្រាក់នៃការពិន័យអន្តរការណ៍នេះ ត្រូវកំណត់លំអិតដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ។

**មាត្រា ៦៧.–**

មន្ត្រីមានសមត្ថកិច្ចដែលមិនគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវទទួលទណ្ឌកម្មខាងរដ្ឋបាល ដោយមិនទាន់គិតពីទណ្ឌកម្មផ្សេងទៀតស្របតាមច្បាប់ និង បទប្បញ្ញត្តិជាធរមានឡើយ ។

**មាត្រា ៦៨.–**

ទេសចរ ឬ អ្នកធ្វើដំណើរកម្សាន្តដែលប្រព្រឹត្តល្មើសនឹងមាត្រា ៥០ នៃច្បាប់នេះ អាចត្រូវលុបចោលទិដ្ឋាការទេសចរណ៍ ហើយបណ្តេញចេញ ឬ ហាមឃាត់វត្តមានក្នុងតំបន់គោលដៅទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេលកំណត់ណាមួយ ដែលមិនលើសពី ០៥ (ប្រាំ) ឆ្នាំ ឬ ជាអចិន្ត្រៃយ៍ ។

**មាត្រា ៦៩.-**

ទេសចរ ឬ អ្នកធ្វើដំណើរកម្សាន្ត ដែលធ្វើឱ្យខូចខាតដល់បរិស្ថាន មរតកវប្បធម៌ ឬ មរតកធម្មជាតិ ត្រូវទទួលខុសត្រូវតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

**មាត្រា ៧០.-**

អ្នកគ្រប់គ្រង ឬ ម្ចាស់មណ្ឌលកម្សាន្តទេសចរណ៍សម្រាប់មនុស្សពេញវ័យ ដែលប្រព្រឹត្តល្មើសនឹងមាត្រា ៥៧ នៃច្បាប់នេះ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ដល់ ១០.០០០.០០០ (ដប់លាន) រៀល ដោយមិនទាន់គិតដល់វិធានការរដ្ឋបាលផ្សេងទៀត ក្នុងករណីមិនរាងចាលត្រូវពិន័យជាប្រាក់ទ្វេដង ។

**មាត្រា ៧១.-**

ប្រតិបត្តិករទេសចរណ៍ដែលមិនអនុញ្ញាត ឬ រារាំងមន្ត្រីអធិការកិច្ចទេសចរណ៍បំពេញការងាររបស់ខ្លួនដូចមានចែងក្នុងច្បាប់នេះ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ដល់ ១០.០០០.០០០ (ដប់លាន) រៀល ដោយមិនទាន់គិតដល់វិធានការរដ្ឋបាលផ្សេងទៀត ក្នុងករណីមិនរាងចាលត្រូវពិន័យជាប្រាក់ទ្វេដង ។

**មាត្រា ៧២.-**

ជនណាដែលបង្កឱ្យមានការប្រព្រឹត្តល្មើស ឬ ការពារអាជីវកម្មទេសចរណ៍ ដែលប្រព្រឹត្តរំលោភនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវប្រឈមនឹងទណ្ឌកម្មខាងរដ្ឋបាល ឬ ការទទួលខុសត្រូវខាងព្រហ្មទណ្ឌ និងសំណងរដ្ឋប្បវេណីដែលមានចែងដោយច្បាប់ និង បទប្បញ្ញត្តិជាធរមានផ្សេងទៀត ។

**មាត្រា ៧៣.-**

ជនណាដែលបន្លំ ឬ បោកបញ្ឆោតក្នុងការលក់ផលិតផល ឬ សេវាកម្មទេសចរណ៍ក្លែងក្លាយដល់ភ្ញៀវ ត្រូវទទួលពិន័យអន្តរការណ៍ដែលមានចំនួនទ្វេដងនៃថ្លៃលក់ផលិតផល ឬ សេវាកម្មទេសចរណ៍ ។ ប្រសិនបើអំពើនោះបង្កើតជាបទល្មើសព្រហ្មទណ្ឌ ត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន ។ ក្នុងករណីនេះ ក្រសួងទេសចរណ៍អាចលុបចោល ឬ ព្យួរ ឬ បញ្ចុះថ្នាក់អាជ្ញាបណ្ណទេសចរណ៍មកជាអាជ្ញាបណ្ណបណ្តោះអាសន្ន ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា ៧៤.-**

ជនណាដែលក្លែងអាជ្ញាបណ្ណទេសចរណ៍ ឬ ឯកសារសាធារណៈផ្សេងៗ ត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន ។

## ជំពូកទី ១១
## អន្តរប្បញ្ញត្តិ

**មាត្រា ៧៥.-**

អាជ្ញាបណ្ណទេសចរណ៍ ដែលចេញដោយក្រសួងទេសចរណ៍ មុនច្បាប់នេះចូលជាធរ-មាន នៅតែមានសុពលភាព និងប្រសិទ្ធភាពរហូតដល់ថ្ងៃអស់សុពលភាព ដូចដែលបានកំណត់នៅលើអាជ្ញាបណ្ណទេសចរណ៍នោះ ។

ប្រតិបត្តិករទេសចរណ៍ទាំងឡាយណា ដែលបើកដំណើរការអាជីវកម្មបម្រើសេវាកម្មទេសចរណ៍ដោយគ្មានអាជ្ញាបណ្ណទេសចរណ៍ ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ក្នុងរយៈពេល ០៣ (បី) ខែ បន្ទាប់ពីច្បាប់នេះចូលជាធរមាន ។

## ជំពូកទី ១២
## អវសានប្បញ្ញត្តិ

**មាត្រា ៧៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៧៧.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៩

នស/រកម.០៦០៩.០០៣

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
រដ្ឋមន្ត្រីក្រសួងទេសចរណ៍

ហត្ថលេខា

ថោង ខុន

លេខ: ៥៨៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

## ឧបសម្ព័ន្ធ

និយមន័យនៃពាក្យ និងវាក្យស័ព្ទមួយចំនួនដែលប្រើក្នុងច្បាប់នេះ មានដូចតទៅ ៖

- **ការលើកទឹកចិត្ត** ៖ សំដៅដល់រង្វាន់ដែលផ្តល់ដោយក្រសួងទេសចរណ៍ក្រោមមាត្រា ២៦ សម្រាប់ជាការលើកទឹកចិត្តដល់បណ្តាអាជីវកម្មទេសចរណ៍ ឬ បុគ្គលដែលមានស្នាដៃ ក្នុងការរៀបចំបានល្អពិសេសៗនូវផលិតផល ឬ សេវាកម្មទេសចរណ៍ ហើយឆ្លើយតបតាមស្តង់ដារធានាគុណភាពផលិតផល ឬ សេវាកម្មទេសចរណ៍ ។

- **ការទទួលខុសត្រូវចម្បង** ៖ សំដៅដល់សមត្ថកិច្ចគ្រប់គ្រងផ្ទាល់របស់ក្រសួងទេសចរណ៍ក្នុងការទទួលខុសត្រូវដឹកនាំគ្រប់គ្រងកិច្ចអភិវឌ្ឍផ្នែកសំខាន់ៗនៃឧស្សាហកម្មទេសចរណ៍ និងដឹកនាំចេញបទប្បញ្ញត្តិគ្រប់គ្រង និងផ្តល់អាជ្ញាបណ្ណទេសចរណ៍ ដូចមានចែងក្នុងមាត្រា ១០ មាត្រា ៣០ (ក) ក្រោមជំពូកទី ៣ និងជំពូកទី ៥ នៃច្បាប់ស្តីពីទេសចរណ៍ ។

- **ការទទួលខុសត្រូវរួមគ្នា** ៖ សំដៅដល់សមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងទេសចរណ៍ដែលត្រូវសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធក្នុងការទទួលខុសត្រូវគ្រប់គ្រងរួមគ្នានូវបណ្តាផ្នែកដែលប៉ះពាល់ទៅលើ ឬ ទទួលរងការប៉ះពាល់ដោយឧស្សាហកម្មទេសចរណ៍ ដោយចេញបទប្បញ្ញត្តិរួមគ្នាដើម្បីបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង ដូចមានចែងក្នុងមាត្រា ១១ មាត្រា ៣០ (ខ) ក្រោមជំពូកទី ៣ និងជំពូកទី ៥ នៃច្បាប់ស្តីពីទេសចរណ៍ ។

- **ការទទួលខុសត្រូវដោយផ្តល់យោបល់** ៖ សំដៅដល់ការទទួលខុសត្រូវរបស់ក្រសួងទេសចរណ៍ ក្នុងការធានាឱ្យបាននូវនិរន្តរភាពនៃការអភិវឌ្ឍវិស័យទេសចរណ៍ ដោយធ្វើការផ្តល់យោបល់ផ្នែកជំនាញទេសចរណ៍ជូនក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធដែលការងាររបស់គេប៉ះពាល់ទៅលើ ឬ ទទួលរងការប៉ះពាល់ដោយឧស្សាហកម្មទេសចរណ៍ដូចមានកំណត់ក្នុងមាត្រា ១២ មាត្រា ៣០ (គ) ក្រោមជំពូកទី ៣ និង ជំពូកទី ៥ នៃច្បាប់ស្តីពីទេសចរណ៍ ។

- **ការទទួលស្គាល់គុណភាព** ៖ សំដៅដល់វិញ្ញាបនបត្រដែលចេញដោយក្រសួងទេសចរណ៍ ឬ ដែលចេញដោយសមាគមឧស្សាហកម្មទេសចរណ៍ ដើម្បីបញ្ជាក់ ទទួលស្គាល់គុណភាពផលិតផល ឬ សេវាកម្មទេសចរណ៍ដែលបានឆ្លើយតបទៅនឹងស្តង់ដារធានាគុណភាពដែលកំណត់ដោយក្រសួងទេសចរណ៍ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

- **ការីទេសចរណ៍** : សំដៅដល់បុគ្គលដែលរៀបចំ និងលក់ខ្សែទស្សនកិច្ចព្រមទាំងប្រមូលផ្តុំសេវាកម្មទេសចរណ៍ផ្សេងៗទៀត សម្រាប់លក់ដោយផ្ទាល់ ឬ តាមរយៈភ្នាក់ងារទេសចរណ៍ ឬភាគីផ្សេងទៀតក្នុងកិច្ចសន្យា ។

- **កម្រៃអាជ្ញាបណ្ណទេសចរណ៍** : សំដៅដល់ប្រាក់ដែលត្រូវបង់ដើម្បីទទួលបានអាជ្ញាបណ្ណទេសចរណ៍ពីក្រសួងទេសចរណ៍ ឬ ពីរដ្ឋបាលថ្នាក់ក្រោមជាតិ ។

- **ក្រមប្រតិបត្តិវិជ្ជាជីវៈ** : សំដៅដល់បញ្ញត្តិដែលត្រូវបានកំណត់ឡើងសម្រាប់ប្រភេទវិជ្ជាជីវៈនីមួយៗនៃឧស្សាហកម្មទេសចរណ៍ ដែលមានចរិតលក្ខណៈជាការកម្រិត ឬ តម្រូវរួមទាំងការពិន័យចំពោះអ្នកដែលបានប្រព្រឹត្តផ្ទុយ មិនបានគោរពអនុវត្តវិជ្ជាជីវៈដែលខ្លួនកំពុងអនុវត្តនោះ ។

- **ក្រមសីលធម៌វិជ្ជាជីវៈ** : សំដៅដល់ច្បាប់ទូទ្មាន ដែលត្រូវបានកំណត់ឡើងសម្រាប់ប្រភេទវិជ្ជាជីវៈនីមួយៗនៃឧស្សាហកម្មទេសចរណ៍ មានចរិតលក្ខណៈជាអភិសមាចារដោយភ្ជាប់ជាមួយនូវការអប់រំ តម្រែតម្រង់ និងពន្យល់ណែនាំប្រតិបត្តិករទេសចរណ៍ ក្នុងគោលបំណងលើកកំពស់ចរិយាមារយាទល្អប្រពៃ ការគោរពអនុវត្តសីលធម៌វិជ្ជាជីវៈ ។

- **ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា** : សំដៅដល់នីតិបុគ្គលមានលក្ខណៈជាដៃគូរវាងផ្នែកឯកជន និងផ្នែកសាធារណៈ ដែលបង្កើតឡើងដើម្បីពង្រឹង ពង្រីក និងអនុវត្តឱ្យមានប្រសិទ្ធភាពសកម្មភាពការងារសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា ។

- **ខ្សែទស្សនកិច្ច** : សំដៅដល់កញ្ចប់សេវាកម្មទេសចរណ៍រៀបចំឡើងដោយការីទេសចរណ៍រួមបញ្ចូលនូវសេវាកម្មយ៉ាងតិចពីរ ក្នុងចំណោមសេវាកម្មចាំបាច់ ដូចជាសេវាកម្មស្នាក់នៅទេសចរណ៍ សេវាកម្មដឹកជញ្ជូន សេវាកម្ម ម្ហូបអាហារ និងភេសជ្ជៈ ការធ្វើទស្សនកិច្ច សេវាកម្មមគ្គុទ្ទេសក៍ទេសចរណ៍ និងសេវាផ្សេងទៀតដែលពាក់ព័ន្ធ ដោយមានថ្លៃលក់មួយជាក់លាក់ និងស្ថិតក្នុងថេរវេលាប្រតិបត្តិជាកំណត់ ។

- **គោលបំណងទេសចរណ៍** : សំដៅដល់គោលបំណងសំខាន់ៗ ដូចជាសម្រាក លំហែកំសាន្ត ទស្សនា សាសនា សកម្មភាពកីឡា ធុរកិច្ច សាកសួរសុខទុក្ខញាតិសន្តាន ព្យាបាលសុខភាព សិក្សាស្រាវជ្រាវ និងគោលបំណងទេសចរណ៍ស្របច្បាប់ផ្សេងៗទៀត ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

- **គោលដៅទាក់ទាញទេសចរណ៍** : សំដៅដល់ទីកន្លែងដែលមានភាពទាក់ទាញទេសចរណ៍ មានសម្បទាទេសចរណ៍ មានសេវាបម្រើប្រកបដោយផាសុកភាព និងមានលទ្ធភាពអាចចូលទៅដល់បាន ។

- **គណៈកម្មការដោះស្រាយវិវាទទេសចរណ៍** : សំដៅដល់អង្គការចាត់តាំងមួយដែលក្រសួងទេសចរណ៍ ត្រូវបង្កើតឡើងដោយផ្អែកលើសេចក្ដីត្រូវការ ដើម្បីទទួលសម្របសម្រួលដោះស្រាយវិវាទ និងការប្រតិបត្តិតាមកាតព្វកិច្ច ក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីទេសចរណ៍ ។

- **គ្រឹះស្ថានសិក្សាទេសចរណ៍ និងបដិសណ្ឋារកិច្ច** : សំដៅដល់គ្រឹះស្ថានសិក្សាជាសកលវិទ្យាល័យ មហាវិទ្យាល័យ វិទ្យាស្ថានដែលបង្កើតឡើងដោយផ្នែកសាធារណៈ ផ្នែកឯកជន ចម្រុះរដ្ឋ ឬ អង្គការមិនមែនរដ្ឋាភិបាលដែលមានការអប់រំបណ្ដុះបណ្ដាលជំនាញទេសចរណ៍ សណ្ឋាគារ និងបដិសណ្ឋារកិច្ច ។

- **តំបន់ទេសចរណ៍** : សំដៅដល់តំបន់ទាំងឡាយក្នុងព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានជ្រើសរើស រៀបចំ និងអភិវឌ្ឍបម្រើឱ្យគោលបំណង និងសកម្មភាពទេសចរណ៍ ។

- **ទេសចរណ៍** : សំដៅដល់សកម្មភាពទាំងឡាយរបស់បុគ្គល ដែលធ្វើដំណើរទៅ និងស្នាក់នៅកន្លែងផ្សេង ក្រៅពីបរិយាកាសប្រក្រតីរបស់គេ សម្រាប់រយៈពេលកំណត់មួយ ដែលមិនលើសពីមួយឆ្នាំជាប់ៗគ្នា ដើម្បីសម្រាក លំហែ កម្សាន្ត ធុរកិច្ច និងគោលបំណងទេសចរណ៍ស្របច្បាប់ផ្សេងៗទៀត ។

- **ទេសចរ** : សំដៅដល់បុគ្គលទាំងឡាយ ជាជនជាតិកម្ពុជា ឬ ជនបរទេសដែលមកដល់តំបន់ផ្សេង ក្រៅពីបរិយាកាសប្រក្រតីរបស់គេ ស្នាក់នៅទីនោះចាប់ពីមួយយប់ឡើងទៅ និងមិនលើសពីរយៈពេលដែលកំណត់ដើម្បីសម្រាកលំហែ កម្សាន្ត ធុរកិច្ច និងគោលបំណងទេសចរណ៍ស្របច្បាប់ផ្សេងៗទៀត ព្រមទាំងមិនទាក់ទងដល់គោលបំណងតាំងទីលំនៅ ឬ ធ្វើសកម្មភាពណាមួយដែលទទួលបានប្រាក់កម្រៃនៅទីនោះ ។

- **បុគ្គល** : សំដៅដល់រូបវន្តបុគ្គល ឬ នីតិបុគ្គល ។

- **ប្រតិបត្តិករទេសចរណ៍** : សំដៅដល់បុគ្គលដែលប្រតិបត្តិ ប្រកបអាជីព ឬ ធ្វើអាជីវកម្មលើសេវាកម្មទេសចរណ៍ ។

- **ផលិតផលទេសចរណ៍** : សំដៅដល់ធនធានដែលមានស្រាប់ ឬ ធនធានដែលបង្កើតឡើងជាអាទិ៍ សម្បត្តិវប្បធម៌ ធនធានធម្មជាតិ សម្បទាសេវាកម្ម ទំនិញ សេវាកម្ម

ផលិតផលផ្សេងៗទៀត ដែលអាចបំពេញសេចក្តីត្រូវការ ការចង់បាន និងការធ្វើសកម្មភាពទេសចរណ៍ ។

- **ផែនការអភិវឌ្ឍទេសចរណ៍ថ្នាក់ជាតិ** : សំដៅដល់ផែនការទាំងមូលសម្រាប់ការគ្រប់គ្រង និងការអភិវឌ្ឍទេសចរណ៍ថ្នាក់ជាតិ រួមបញ្ចូលដោយគោលនយោបាយ ផែនការ និងយុទ្ធសាស្ត្រ ដែលក្រសួងទេសចរណ៍បានរៀបចំ ។

- **ផែនការអភិវឌ្ឍទេសចរណ៍ថ្នាក់តំបន់** : សំដៅដល់ផែនការទូទៅសម្រាប់ការគ្រប់គ្រង និងការអភិវឌ្ឍទេសចរណ៍ក្នុងតំបន់បានកំណត់មួយ រួមបញ្ចូលដោយគោលនយោបាយ ផែនការ និងយុទ្ធសាស្ត្រដែលក្រសួងទេសចរណ៍បានរៀបចំ ។

- **ផែនការអភិវឌ្ឍទេសចរណ៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ** : សំដៅដល់ផែនការទូទៅសម្រាប់ការគ្រប់គ្រង និងការអភិវឌ្ឍទេសចរណ៍ ក្នុងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌមួយ រួមបញ្ចូលដោយគោលនយោបាយ ផែនការ និងយុទ្ធសាស្ត្រ ដែលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនោះ និងក្រសួងទេសចរណ៍បានរៀបចំ ។

- **ភាពទាក់ទាញទេសចរណ៍** : សំដៅដល់សម្បត្តិវប្បធម៌ ធនធានធម្មជាតិ ព្រឹត្តិការណ៍ អាជីវកម្ម ទីបរិវេណ បរិក្ខារប្រើប្រាស់ ឬ ភាពទាក់ទាញផ្សេងៗទៀត ដែលមានលក្ខណៈពិសេស សម្រាប់បម្រើឱ្យការសម្រាក លំហែ កម្សាន្ត និង គោលបំណងទេសចរណ៍ស្របច្បាប់ផ្សេងៗទៀត ។

- **ភ្នាក់ងារទេសចរណ៍** : សំដៅដល់បុគ្គលមានសញ្ជាតិខ្មែរ ដែលធ្វើអាជីវកម្មជាអ្នកជួយលក់សេវាកម្មទេសចរណ៍ ដូចជា សំបុត្រមធ្យោបាយធ្វើដំណើរ សេវាកម្មស្នាក់នៅទេស-ចរណ៍ និងសេវាកម្មទេសចរណ៍ផ្សេងៗទៀត រាប់បញ្ចូលខ្សែទស្សនកិច្ចដែលបង្កើតដោយការីទេសចរណ៍ផងដែរ ។

- **ភ្ញៀវ** : សំដៅដល់បុគ្គលដែលធ្វើដំណើរដើម្បីសម្រាក លំហែ កម្សាន្ត ធុរកិច្ច និងគោលបំណងទេសចរណ៍ស្របច្បាប់ផ្សេងៗទៀត ក្នុងនាមជាទេសចរ ឬ ជាអ្នកធ្វើដំណើរកម្សាន្ត ។

- **មគ្គុទ្ទេសក៍ទេសចរណ៍** : សំដៅដល់បុគ្គលដែលប្រកបអាជីព ជាអ្នកទទួល ជូនដំណើរភ្ញៀវជាតិ អន្តរជាតិ និងធ្វើអត្ថាធិប្បាយពន្យល់អំពីភូមិសាស្ត្រ ធម្មជាតិ ប្រវត្តិសាស្ត្រ វប្បធម៌ ប្រពៃណី សិល្បៈ ទំនៀមទម្លាប់ និងសេដ្ឋកិច្ច សង្គមនៃទីកន្លែងទស្សនា ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

Ksl

- **មណ្ឌលកម្សាន្តទេសចរណ៍** : សំដៅដល់ទីតាំងសេវាកម្មទាំងឡាយ ដែលធ្វើអាជីវកម្មបម្រើឱ្យការសម្រាក លំហែ និងកម្សាន្ត តាមគោលបំណងទេសចរណ៍ ស្របច្បាប់ ហើយប្រភេទអាជីវកម្មទាំងនោះ ត្រូវបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ។

- **មណ្ឌលកម្សាន្តទេសចរណ៍សម្រាប់មនុស្សពេញវ័យ** : សំដៅដល់ទីតាំងសេវាកម្មទាំងឡាយដែលធ្វើអាជីវកម្មបម្រើឱ្យការសម្រាក លំហែ និងកម្សាន្តសម្រាប់មនុស្សពេញវ័យ ហើយប្រភេទអាជីវកម្មទាំងនោះត្រូវបានកំណត់ដោយអនុក្រឹត្យ ។

- **មូលដ្ឋានសេវាកម្មម្ហូបអាហារ និងភេសជ្ជៈ** : សំដៅដល់អាហារដ្ឋាន ភោជនីយដ្ឋាន អគារ ឬ ទីតាំងសម្រាប់ពិធីជប់លៀង ឬ សមោសរ ដែលបើកដំណើរការបម្រើសេវាកម្មម្ហូបអាហារ និងភេសជ្ជៈ ឬ សេវាកម្មកម្សាន្តដទៃទៀតសម្រាប់ភ្ញៀវ ។

- **មូលដ្ឋានសេវាកម្មស្នាក់នៅទេសចរណ៍** : សំដៅដល់សណ្ឋាគារ អាផាត់ម៉ិន ម៉ូតែល ផ្ទះសំណាក់ ឡូជ បឹងកាឡូ កន្លែងបោះជំរំ និងកន្លែងសម្រាកស្នាក់នៅសម្រាប់ទេសចរណ៍ផ្សេងទៀត ។

- **រង្វាន់** : សំដៅដល់រង្វាន់ ដែលឧបត្ថម្ភដោយក្រសួងទេសចរណ៍ ក្រោមមាត្រា ២៦ នៃច្បាប់នេះ សម្រាប់ជាការទទួលស្គាល់អាជីវកម្មទេសចរណ៍ ឬ បុគ្គលដែលមានស្នាដៃពិសេសក្នុងការអនុវត្តតាមនូវស្តង់ដារធានាគុណភាពផលិតផល ឬ សេវាកម្មទេសចរណ៍ ដែលបានកំណត់ដោយក្រសួងទេសចរណ៍ ។

- **រមណីយដ្ឋានទេសចរណ៍** : សំដៅដល់ទីតាំងដែលមានភាពទាក់ទាញទេសចរណ៍ ដូចជាវប្បធម៌ ប្រវត្តិសាស្ត្រ ធម្មជាតិ ឆ្នេរសមុទ្រ ឬ ដែលរៀបចំកែច្នៃឡើង ហើយត្រូវបានអនុញ្ញាតឱ្យរៀបចំសម្រាប់ធ្វើអាជីវកម្ម បម្រើឱ្យការសម្រាក លំហែ និងកម្សាន្ត តាមគោលបំណងទេសចរណ៍ស្របច្បាប់ ។

- **រដ្ឋបាលថ្នាក់ក្រោមជាតិ** : ក្នុងច្បាប់នេះ សំដៅដល់រដ្ឋបាលរាជធានី រដ្ឋបាល ខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលខណ្ឌ ។

-**លក្ខខណ្ឌអនុវត្តដ៏ប្រសើរបំផុតនៅក្នុងព្រះរាជាណាចក្រកម្ពុជា** : សំដៅដល់លក្ខខណ្ឌអនុវត្តទាំងឡាយ ដែលត្រូវធានាឱ្យ បានទូវការធានាគុណភាព សន្តិសុខ សុវត្ថិភាព ផាសុកភាព ហើយ ដែលមិនផ្ទុយទៅនឹងបរិស្ថាន វប្បធម៌ ទំនៀមទម្លាប់ សណ្តាប់ធ្នាប់សាធារណៈ

- **ទិន្នន្យាស្ថានជាតិទេសចរណ៍** : សំដៅដល់មណ្ឌលសិក្សា និងស្រាវជ្រាវអំពីវិស័យទេសចរណ៍ក្នុងគោលបំណងបង្កើតគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍទេសចរណ៍ប្រកបដោយប្រសិទ្ធភាព គុណភាព និងនិរន្តរភាព ។

- **សមាគមឧស្សាហកម្មទេសចរណ៍** : សំដៅដល់នីតិបុគ្គលជាតំណាងឱ្យក្រុមអាជីវកម្មទេសចរណ៍ដែលមានប្រភេទ និងសកម្មភាពប្រហាក់ប្រហែលគ្នា ហើយបង្កើតឡើងក្នុងគោលបំណងជំរុញ និងការពារផលប្រយោជន៍រួមរបស់ក្រុមខ្លួន ។

- **សាកលវិទ្យាល័យទេសចរណ៍ និងបដិសណ្ឋារកិច្ច** : សំដៅដល់គ្រឹះស្ថានឧត្តមសិក្សាដែលមានការអប់រំ និងបណ្តុះបណ្តាលធនធានមនុស្សលើគ្រប់ជំនាញវិស័យទេសចរណ៍ សណ្ឋាគារ និងបដិសណ្ឋារកិច្ច ។

- **សាលាវិជ្ជាជីវទេសចរណ៍** : សំដៅដល់គ្រឹះស្ថានសិក្សាដែលបង្កើតឡើងដោយផ្នែកសាធារណៈ ផ្នែកឯកជន ចម្រុះរដ្ឋ ឬ អង្គការមិនមែនរដ្ឋាភិបាល ដែលមានការអប់រំបណ្តុះបណ្តាល អ្នកឯកទេសវិជ្ជាជីវៈទេសចរណ៍ សណ្ឋាគារ និងបដិសណ្ឋារកិច្ចសំដៅបម្រើឱ្យឧស្សាហកម្មទេសចរណ៍ ។

- **សេវាកម្មដឹកជញ្ជូនក្នុងស្រុក** : សំដៅដល់អាជីវកម្មរៀបចំឡើង ដើម្បីបម្រើសេវាកម្មដឹកជញ្ជូនតាមផ្លូវគោក និងផ្លូវទឹក សម្រាប់ប្រជាពលរដ្ឋទូទៅ និង ដោយរួមទាំងទេសចរផងដែរ ។

- **សេវាកម្មដឹកជញ្ជូនទេសចរណ៍** : សំដៅដល់អាជីវកម្មរៀបចំឡើង ដើម្បីបម្រើសេវាកម្មដឹកជញ្ជូនសម្រាប់ទេសចរណ៍ តាមផ្លូវគោក និងផ្លូវទឹក ដោយរួមទាំងនាវាទេសចរណ៍សមុទ្រផងដែរ ។

- **សហគមន៍ទេសចរណ៍មូលដ្ឋាន** : សំដៅដល់ទីតាំង ឬ កន្លែងទាក់ទាញទេសចរណ៍ដែលរៀបចំដោយសហគមន៍មូលដ្ឋានខ្លួនឯងផ្ទាល់ ឬ ដោយមានកិច្ចសហប្រតិបត្តិការ ដើម្បីពង្រឹងកិច្ចអភិវឌ្ឍមូលដ្ឋាន ក្នុងគោលបំណងកាត់បន្ថយភាពក្រីក្រ និងលើកស្ទួយជីវភាពរស់នៅរបស់សហគមន៍ និងបម្រើផលប្រយោជន៍ប្រជាពលរដ្ឋមូលដ្ឋាន តាមរយៈការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាព ។

- **ស្លាកសញ្ញាបញ្ជាក់គុណភាព** : សំដៅដល់សញ្ញាដែលកំណត់ដោយក្រសួងទេសចរណ៍ស្ថិតក្រោមមាត្រា ២៦ នៃច្បាប់នេះ ដើម្បីសម្គាល់ពីគុណភាពនៃផលិតផល/សេវាកម្មទេសចរណ៍ ត្រូវប្រើប្រាស់សម្រាប់ប្រភេទនីមួយៗនៃអាជីវកម្មផ្សេងៗ នៅក្នុងឧស្សាហកម្ម

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ទេសចរណ៍ ហើយបានឆ្លើយតបទៅនឹងស្តង់ដារធានាគុណភាពផលិតផល/សេវាកម្មទេសចរណ៍ ។

- **ស្លាកសញ្ញាពិសេស** : សំដៅដល់សញ្ញាដែលកំណត់ដោយក្រសួងទេសចរណ៍ ក្រោមមាត្រា ២៦ នៃច្បាប់នេះ ដើម្បីសម្គាល់ពីលក្ខណៈពិសេស និងគុណសម្បត្តិពិសេសផ្សេងៗទៀតនៃផលិតផលទេសចរណ៍ ពិនិត្យឃើញថាឆ្លើយតបទៅនឹងស្តង់ដារធានាគុណភាពផលិតផល/សេវាកម្មទេសចរណ៍ ។

- **អនីតិជន** : សំដៅដល់ជនដែលមានអាយុក្រោម ១៨ ឆ្នាំ ។

- **អាជីវកម្មទេសចរណ៍** : សំដៅដល់អាជីវកម្មលើសេវាកម្មទេសចរណ៍ មានចែងក្នុងមាត្រា ៣០ នៃច្បាប់ស្តីពីទេសចរណ៍ ។

- **អាជ្ញាបណ្ណទេសចរណ៍** : សំដៅដល់អាជ្ញាបណ្ណ ដែលចេញឱ្យដោយក្រសួងទេសចរណ៍ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិ ក្រោមមាត្រា ៣០ នៃច្បាប់នេះ ជាអាជ្ញាបណ្ណពេញសិទ្ធិ ឬ អាជ្ញាបណ្ណបណ្ដោះអាសន្ន ។

- **អាហារដ្ឋាន និងភោជនីយដ្ឋានទេសចរណ៍** : សំដៅដល់អគារ ឬ ទីតាំងដែលរៀបចំឡើងដើម្បីបម្រើសេវាកម្មម្ហូបអាហារ និងភេសជ្ជៈ សម្រាប់ភ្ញៀវជាចម្បង ។

- **អាហារដ្ឋាន និងភោជនីយដ្ឋានទទួលបម្រើភ្ញៀវក្នុងស្រុក** : សំដៅដល់អគារ ឬ ទីតាំង ដែលរៀបចំឡើងដើម្បីបម្រើសេវាកម្មម្ហូបអាហារ និងភេសជ្ជៈ សម្រាប់ប្រជាពលរដ្ឋទូទៅជាចម្បង ។

- **អេកូទេសចរណ៍** : សំដៅដល់ទម្រង់ទេសចរណ៍ផ្អែកលើធម្មជាតិ ដែលមានគោលបំណងអភិរក្សបរិស្ថានធម្មជាតិ និងវប្បធម៌តំបន់ ជួយលើកកម្ពស់ជីវភាពរស់នៅ សុខុមាលភាពរបស់ប្រជាពលរដ្ឋមូលដ្ឋាន ផ្តល់បទពិសោធន៍ល្អដល់ទេសចរ និងការធ្វើដំណើរប្រកបដោយការទទួលខុសត្រូវ និងកម្សាន្ត កោតសរសើរ រៀនសូត្រពីធម្មជាតិ ។

- **អេកូឡាបិល** : សំដៅដល់ស្លាកសញ្ញាបរិស្ថានពិសេស ដែលកំណត់ដោយក្រសួងទេសចរណ៍ ក្រោមមាត្រា ២៧ សម្រាប់ផលិតផលអេកូទេសចរណ៍ ។

- **អ្នកធ្វើដំណើរកម្សាន្ត** : សំដៅដល់បុគ្គលទាំងឡាយ ជាជនជាតិកម្ពុជា ឬ ជនបរទេស ដែលធ្វើដំណើរទៅកាន់តំបន់ណាមួយដើម្បីសម្រាក លំហែ កម្សាន្ត ធុរកិច្ច និងធ្វើសកម្មភាពទេសចរណ៍ស្របច្បាប់ផ្សេងៗទៀត ក្នុងអំឡុងពេលតិចជាងមួយយប់ ។

- **អ្នកនាំក្រុមទេសចរ** : សំដៅដល់បុគ្គលដែលការីទេសចរណ៍ បានចាត់ឱ្យបំពេញតួនាទី និងភារកិច្ចជាអ្នកនាំក្រុមទេសចរ ក្នុងរយៈពេលនៃការប្រើប្រាស់ខ្សែទស្សនកិច្ចជួយសម្របសម្រួល និងបង្កភាពងាយស្រួលដល់ការអនុវត្តការងារនៃមគ្គុទ្ទេសក៍ទេសចរណ៍ ។

- **អ្នកទទួលដោះស្រាយវិវាទ** : សំដៅដល់មន្ត្រីដែលត្រូវបានតែងតាំងដោយរដ្ឋមន្ត្រីក្រសួងទេសចរណ៍ ដើម្បីទទួលតួនាទីជាអ្នកទទួលដោះស្រាយវិវាទទេសចរណ៍ ដូចមានចែងនៅក្នុងមាត្រា ៥៤ និង មាត្រា ៥៥ នៃច្បាប់ស្តីពីទេសចរណ៍ ។

- **ឧស្សាហកម្មទេសចរណ៍** : សំដៅដល់ផ្នែកមួយនៃឧស្សាហកម្មសេវាកម្ម ដែលបង្កើតឡើងក្នុងគោលបំណងផ្គត់ផ្គង់ដល់សេចក្តីត្រូវការរបស់ទេសចរ និងសង្គម ដោយរួមមានជាសម្បទា ឬ សេវាកម្មទាំងឡាយដែលពាក់ព័ន្ធដោយផ្ទាល់ និង ដោយប្រយោលដល់ការអភិវឌ្ឍវិស័យទេសចរណ៍ និងជួយបង្កឱ្យមានភាពអាចអនុវត្តទៅបាននៃខ្សែទស្សនកិច្ច ។

ROYAUME DU CAMBODGE
LE MINISTÈRE DU PALAIS ROYAL